នៅក្រោមដើមឈើធំ ឯកមានកេះនាងឱ្យសំងំស្ងៀម ទាំងភ្នែកនៅកញ្ចឹងក។ ផានូ ឃើញម្នាក់នោះសម្លឹងចុះឡើង មុនពេលចុចប៊ូតុងស៊ីប្លេហើយគ្នាវាបកមកវិញជាបន្តបន្ទាប់ បញ្ឆាំងហ្វាម៉ូតូភ្លឺចិញ្ចាច។

ឯកមានមើលទៅទៅទីតាំងកង់កញ្ចាស់ជាអំណោយពីអ្នកស្រុក។

គេដឹងថាគ្រោះថ្នាក់នៅកៀកបង្កើយ គឺកង់នេះពួកនោះងាកតែមួយខ្ទាច់មកក៏អាចរកឃើញតែម្តង។

«យើងរកកន្លែងរត់»

គេនិយាយទាំងងាកឆ្វេងស្តាំរកច្រកគេចចេញមុនពេលពួកនោះឃើញកង់ហើយនឹងឃើញទាំងមនុស្ស។ ដៃនាងពិតជាត្រជាក់ដូចមនុស្សស្លាប់....ស្ថានភាពនៅពេលនេះគ្មានខុសអ្វីនឹងចុះទឹកក្រពើឡើងលើខ្លា។ ការរត់គេចមួយយប់ហើយនៅតែមិនអាចបញ្ចប់បាន....

វគ្គ វាសនាLorenZo

ជំនួយការវឌ្ឍនៈ នៅក្នុងការ ប្រញាប់ប្រញាល់ចូលរកLorennnzoដល់បន្ទប់ទឹកពេលគេកាន់ដង

កោរ ពុកចង្កាមកហៀបនឹងដំណើរការ។

«Rose ឧលមក!»

បុរសសង្ហា ជាតារាសប្បុរសក្នុងដួងចិត្តស្រីៗ ងាកមកជាមួយ ពុកមាត់ដែលប្រឡាក់ស្រមូមជាមួយពពុះប្រេងសម្រាប់កោរសំអាត។

គេមានខ្សែភ្នែកទន់ភ្លន់ដែលបញ្ចេញរស្មីស្ងប់ស្ងាត់នៅក្រោមរោមចិញ្ចើមក្រាស់សិចស៊ី តែគេពិតជាភ្ញាក់ផ្អើលណាស់ពេលឮឈ្មោះនាង៖

«នាងឯនៅណាRose?»

នាងទើបតែដឹងថា គេមិនទាន់បានដឹងឮអ្វីអំពីការរំដោះដ៏ធំចេញពីល្អាងនោះទំនងជាប៉ូលិសនៅលាក់ការណ៍ដើម្បីអង្កេត ឬមួយយ៉ាងណា?

«កុំខ្វល់ពីខ្ញុំ! គិតពីខ្លួនលោក! ពួកចោរមួយក្រុមដែលប៉ងចាប់កូនស្រីមេប៉ូលិសបានសារភាពថា ពួកគេជាមនុស្សរបស់ដេវីត ពេលនេះដេវីតឆ្លើយដាក់លោកថាលោកជាអ្នកប្រើគេឱ្យចាប់ស្រីៗហើយនឹងសម្លាប់មហាវីនបំបិទមាត់!»

«ឆ្កួតសុទ្ធ!»

គេនិយាយតិចៗ ហើយងាកមករកវឌ្ឍនៈ។ ជំនួយការបើកភ្នែកមូលក្រឡង់តាមរបៀបងឿងឆ្ងល់ដោយលូកដៃមកចុចទូរសព្ទឱ្យខ្លួនគេនេះបានឮដែរ។

«មានគេរៀបគម្រោងទម្លាក់កំហុសលើលោកច្បាស់ណាស់! តែលោកគ្មានពេលស្វែងរកទេ! ប៉ូលិសកំពុងរៀបចំចេញទៅឃាត់ខ្លួនលោក Lorenz ! ស្ដាប់! លោកត្រូវគេចចេញសិន កុំធ្លាក់ក្នុងដៃគេឱ្យសោះ ឮអត់ ! អន្ទាក់នេះជ្រៅណាស់! វាជាអន្ទាក់! ខ្ញុំនិយាយមិនបានច្រើនទេ! លោកត្រូវចេញពីស្រុកខ្មែរតែកុំជិះយន្តហោះអូខេ!»

ទូរសព្ទត្រូវបានកាត់ផ្ដាច់។

សូម្បីតែពេលនេះនាងនៅឯណាក៏គ្មានចម្លើយ?

«អ្នកណាធ្វើអ្វះបងវឌ្ឍនៈ? អាមហាវីន? ខ្ញុំដែលទាក់ទងអាដេវីតណាមួយពីអង្កាល់ ហេតុអីប៉ូលិសសួរវាឆ្លើយដាក់ខ្ញុំ?»

Lorenzo ងាកមកសួរជំនួយការដែលកំពុងតែស្លេកមុខ ធ្វើឱ្យគេនោះរឹតតែមានអារម្មណ៍តឹងតែង។

វឌ្ឍនៈព្យាយាមសម្រួលចិត្តហើយដោះស្រាយរឿងរ៉ាវដ៏ធំនៅចំពោះមុខនេះជាដំណាក់កាលៗ៖

«Rose និយាយរួចហើយ! អ្នកណាម្នាក់កំពុងលេងយើង! ខ្ញុំត្រូវទៅរៀបចំឡាន! អ្នកប្រុសតូចចេញពីកន្លែងនេះសិនទើបបាន!»

Lorenzonនៅតែតវ៉ាគេលើកដៃជូតសំអាតពពុះពណ៌សចេញស្រលះពីមាត់បង្ហាញផ្ទៃមុខពេញដោយកំហឹង៖

«ខ្ញុំធ្វើអីខុសហេតុអីពាក្យគេប៉ុន្មានម៉ាត់ខ្ញុំត្រូវរត់?»

«Roseថា ប៉ូលិសកំពុងមកទីនេះឃាត់ខ្លួនអ្នកប្រុសតូច! បើគេគ្មានភស្តុតាង គ្មានតម្រុយគេមិនអាចឃាត់ខ្លួនអ្នកប្រុសតូចទេ!»

«អ៊ីចឹងយើងខ្លាចធ្វើអី? ខ្ញុំស្អាតស្អំ បងឯងឱ្យខ្ញុំរត់ដូចឱ្យខ្ញុំទទួលស្គាល់ថាបានធ្វើខុស!»

វឌ្ឍនៈខំអោនមកពន្យល់៖

«អ្នកប្រុស! នេះជាស្រុកខ្មែរ! ស្អីក៏អាចកើតឡើងបានដែរ! Roseប្រាប់ហើយ អ្នកប្រុសត្រូវគេដាក់អន្ទាក់ដូចរឿងលោកប្រុសធំកាលពីអតីតកាល! បើអ្នកប្រុសចូលដល់ដៃប៉ូលិសហើយ ខ្លាចក្រែងគ្រប់យ៉ាងពិបាកដោះស្រាយ»

គេស្រមៃដល់ឪពុកខ្លួន គាត់ជារឿយៗរំលឹកដល់រឿងនោះហើយមិនសូវសប្បាយចិត្តទេពេលដែលកូនប្រុសតែម្នាក់គត់មកលេងស្រុកខ្មែរ។

ពេលនេះ គ្មានប៉ូលិសវិទូទៀតទេ សម្រាប់លាងភាពស្អាតស្អំឱ្យអ្នកណាម្នាក់។Lorennzo គ្រប់គ្រងអារម្មណ៍តក្កមាហើយទាញកន្សែងមកជូតមាត់សំអាតមុខ ។

ភាគទី៣៥

«ខ្ញុំនឹងមានគ្រោះថ្នាក់មែនអត់?»

«គេចសិនចាំគិត!»

វឌ្ឍនៈឆ្លើយទាំងក្រឡេកក្រឡាប់៖

«Rose ក៏អ៊ីចឹងនិយាយលឹបក្បាលលៀនកន្ទុយ រកគិតអីក៏មិនយល់?»

បុរសជាជំនួយការដាក់ម្រាមដៃមួយទៅបបូរមាត់ស៊ីញ៉ូឱ្យថៅហ្វាយបញ្ចប់ការបញ្ចេញសំឡេង ហើយខ្លួនគេរត់ចេញទៅក្រៅ។

សំឡេងអាយកូមឡាន់មកពីរានហាល ៖

«បង! ឡានប៉ូលិសនៅប្រហែល៥០០ម៉ែត្រពីមាត់ផ្លូវ!»

អ្នកណាម្នាក់ដែលវឌ្ឍនៈដាក់ឱ្យរាយការណ៍ ទំនងជាបោះដៃមក។ ដូច្នេះLorenzoអាចយល់បានថា Rose មិនមានពេលច្រើនទេក្នុងការផ្ញើដំណឹង។

«ព្រះអើយ!»

គេលាន់មាត់ទាំងសៅហ្មងហើយចាប់ផ្ដើមស្លៀកពាក់។

«ម៉ូតូឌុបដែលយើងពង្រាយ ឃើញឡានបីគ្រឿងប្រើស្លាកប៉ូលិសនៅកន្លះគីឡូដីពីកន្លែងយើងទាន!ខ្ញុំត្រូវចាត់ការសិន»

វឌ្ឍនៈចាកចេញពេលLorenzរកពាក្យនិយាយមិនឃើញ។ បន្ទាប់មកគេវិលមកវិញជាមួយសម្ពាយមួយ។

«របស់របរសំខាន់ៗ ខ្ញុំទុកក្នុងនេះអស់ហើយ! លិខិតឆ្លងដែន និងឯកសារផ្សេងទៀត! ខ្ញុំចុះទៅពន្យារពេលប៉ូលិស អ្នកប្រុសចេញតាមទ្វារក្រោយ! ឡានយើងមកដល់ហើយ»

ដៃនាយរៀបចំឡេបថប ហើយរាវរកលិខិតឆ្លងដែន។ គេទទួលកាតាបហើយស្ពាយចុះរឹង មកដល់ទ្វារក្រោយ។

គេឃើញឡានមួយមិនធ្លាប់ស្គាល់កំពុងសំចតរង់ចាំនៅខាងក្រៅរបងផ្ទះរួចជាស្រេច។ នៅតាមចំហៀងខាងឆ្វេង បុរសម្នាក់ស្ទុះចេញមកបកទ្វារឡានឱ្យនាយជាមួយទឹកមុខម៉ឺងម៉ាត់៖

«លោកវឌ្ឍនៈហៅខ្ញុំមកទាន!»

Lorenz ជ្រួញចិញ្ចើម។

គេយល់ថាវឌ្ឍនៈធ្វើការរហ័សពេកហើយ?

ប៉ុន្តែសូហ្វ័របានបញ្ចប់ការសង្ស័យរបស់គេ ដោយបង្ហាញអេក្រង់ទូរសព្ទ លេខរបស់វឌ្ឍនៈដែលទើបនឹងខលទៅគេមុននេះ។ ការជិះឡានចម្លែកគឺជាមធ្យោបាយល្អ នឹងគ្មានអ្នកណាស្គាល់ចាប់អារម្មណ៍តាមមកទេ ។

គេគិតនឹកសរសើរការងារវៃឆ្លាតរបស់ជំនួយការក្នុងពេលដំណាលគ្នា។

Lorenzoលូកដៃស្ទាបដើម្បីឱ្យប្រាកដថាកុំព្យូទ័រសំណព្វរបស់គេក្នុងកាតាបដដែល មុនពេលសម្រេចចិត្ត ឈានជើងឡើងជំនិះដោយគ្មានការសង្ស័យអ្វី។ ជំនិះចេញលឿនតាម ថ្វីដៃបើកបរដ៏អស្ចារ្យហើយបោលកាត់មហាវិថីព្រះនរោត្តមមុនពេលចាកចេញពីរាជធានីភ្នំពេញឆ្ពោះទៅភាគពាយព្យ។

ក្នុងពេលទិសដៅកាន់តែសម្រុកឆ្ងាយឡើងៗឥតឈប់ឈរនេះ ប្រុសស្អាតរាវរកទូរសព្ទប្រុង និយាយទៅអាមេរិកដែរ តែចិត្តគេមួយអាក់ខានវិញព្រោះ.....

«ឱ្យតែយើងហ៊ាននិយាយមិនស្រួលតែបន្តិច ឪពុកម្តាយយើងនឹងលំបាកឡើងមកភ្នំពេញភ្លាមមិនខាន! យើងមិនដឹងទេថា អ្វីទៅនឹងកើតឡើងចំពោះពួកគាត់!»

គេលែងដៃពីទូរសព្ទហើយនឹកឃើញដល់អ្នកដែលបានផ្តល់ដំណឹងមកមុននេះ....គេខលទៅលេខនាង ខលមិនចូល ចំណែកលេខដែលនាងខលមកមុននេះជាលេខលើតុ ....

គេចាប់ផ្តើមបើកLaptopរុករកប្រភពថាលេខនេះមកពីកន្លែងណា....

ការជ្រៀតរកភាពអាថ៌កំបាំងបង្កប់លើបណ្តាញInternetមិនលំបាកប៉ុន្មានឡើយសម្រាប់បុរសនេះ។ទីបំផុត គេដឹងពីប្រភពរបស់នាង....

«ទូរសព្ទបណ្តាញរបស់ប៉ូលិស?»

គេចុចបន្ថែម.....

«ផ្ទះស្នងការRoy?»

គេរអ៊ូម្នាក់ឯងក្នុងចិត្តស្ងាត់ៗ៖

«នាងនិងអាស្នងការចរិតស្រីហ្នឹង មានទំនាក់ទំនងអីនឹងគ្នាអ្ហះRose?»

បុរសអាណិកជនបិទកុំព្យូទ័រវិញទាំងក្តៅក្រហល់ចិត្ត....

នៅខាងណេះវិញ មេពីធីកាដាក់ទូរសព្ទចុះសឹងមិនទាន់ នាងត្រូវភ្ញាក់ដូចជាន់ចំពស់វែកព្រោះថា ដង្ហើមនាយស្នងការលាន់មកពីក្រោយខ្នងទៅហើយ។

មិនដឹងគេចូលមកទាន់ឮពីសេចក្តីរាយការណ៍ របស់នាងទៅកាន់Lorenzoដែលឬក៏អត់ទេ....

«ខ្ញុំគិតអីចេះខុស!»

Royនិយាយក្នុងសព្ទសំឡេងសៅហ្មង។ នាងមិនបានបញ្ចេញអាការៈថា នាងខ្វល់ពីអ្វីដែលគេគិតសោះឡើយ។ ស្រស់ស្រី ប្រញាប់ងាកទៅរកទ្វារហើយសម្លឹងចុះឡើងក្រែងមានអ្នកណាមកតាមពីក្រោយ។

ស្នងការនៅតែជាស្នងការ ទោះគេក្មេងបន្តិច ឬកញ្ចប់រទៀសបើសបន្តិចទៅកាន់អ្នកដែលគេមិនពេញចិត្ត តែគេមានកម្រិតប្រុងប្រយ័ត្នខ្ពស់ជានិច្ច។ ពិសេសពេលដែលគេដឹងថានារីនេះជាអ្នកណា។

នាងធ្វើអាការៈ ដូចចាត់ទុកគេថាជាគ្នាឯងពិតៗហើយនិយាយខ្សឹបៗ៖

«ឱត សាម៉ុននៅឯណា?»

«ខ្លាចគាត់ចាប់នាង?»

Royសួរដោយមុខខឹង។ គេចេះអត់ធ្មត់ចំពោះRoseប៉ុនណានៅតែមិនអាចគ្របដណ្ដប់លើភ្លើងច្រណែនប្រច័ណ្ឌបាន។ Roseជានារីដ៏សែនឆ្លាត នាងមិនមែនមិនដឹងទេថា Royកំពុងខឹង Lorenzoឆាបឆួល។

តែនាងនៅតែនិយាយហេតុផល៖

«លោកក៏ដឹងដែរ អាណិកជននោះត្រូវរងអយុត្តិធម៌!»

«ទុកឱ្យតុលាការសម្រេច! មិនមែននាងទេRose!»

«ខ្ញុំមិនជឿទេ តុលាការស្រុកលោក!»

គេខឹងឆ្អែតហើយ។

នារីនេះមានចរិតដើមជាមនុស្សដែលមើលទៅចាស់ចិត្តគំនិត និយាយស្ដីអ្វីក៏ ដូចជា ប្រើហេតុផល ប្រើភាពប្រាកដនិយមជាជាងអារម្មណ៍ ប៉ុន្តែនារីដដែលនេះដូរមករាយមាយបានដោយសារតារាសប្បុរសម្នាក់គួរឱ្យទើសភ្នែកនោះ។

ស្នងការនិយាយទាំងខឹង៖

«ខ្ញុំមិនជួយយកអាសាអ្នកណាម្នាក់ ឱ្យមកដេកលើផ្ទះខ្ញុំ ហើយប្រើទូរសព្ទខ្ញុំ លួចស្ដាប់ព័ត៌មានពីខ្ញុំ បំផ្លាញការងារខ្ញុំនោះទេ!»

ស្រីសិចស៊ីនៅស្ងៀមសម្លក់គេ។ នាងសម្លឹងបន្ទប់នេះមួយឆ្វាចហើយនិយាយដាច់ខាត៖

«ខ្ញុំទៅក៏បាន!»

នាងចិត្តរឹងណាស់ គេដឹង។ នាងមិនដូចមនុស្សស្រីឯទៀតទេ គេក៏យល់។ មិនសមថាយកភ្លើងប្រចណ្ឌមកគ្របនាង គឺវាបានត្រឹមតែឆេះ។ នាងឈានចេញជាមួយអាវវែងស្តើង សឹងថាមើលធ្លុះឃើញរាងកាយស្អាតគ្មានគូប្រៀបរបស់នាង។

បុរសលូកដៃទាញប្រាណដ៏សិចស៊ីនោះមកអោបជាប់ពីក្រោយទាំងរកពាក្យអ្វីមកនិយាយឃាត់មិនបានសូម្បីតែមួយម៉ាត់ណា។

មេពិធីការពិបាកចិត្តណាស់នៅក្នុងរង្វង់ដៃរបស់គេ ដែលនាងស្តាប់ដឹងថែមទាំងយល់ច្បាស់ពីនៃការទាមទារនៃសម្រែកបេះដូងគេ។

ចរិតRoseជាមនុស្សមិនទម្លាប់លាក់លៀមការពិត ដូច្នេះនាងនិយាយខ្លីៗ៖

«ខ្ញុំស្រលាញ់គេRoy!»

បេះដូងស្នងការត្រូវមួយគ្រាប់នេះផាំង សឹងស្រយុតអស់ជើងដៃរាងកាយ។

ប្រការដែលនាងស្រលាញ់ប្រុសស្អាតដែលស្រីៗជាច្រើនបានដេកនឹកម្នាក់នោះ គេមិនប្រកាន់ទេ ប៉ុន្តែគេមិនចង់ឮវាចេញផ្ទាល់ពីមាត់នារីគត់មត់ម្នាក់នេះដាច់ខាត។

«នាងដឹងហើយថាខ្ញុំឈឺ ហេតុអីរាល់ពេលជួបគ្នានៅតែប្រើសម្តីមកឱ្យខ្ញុំឈឺ?»

គេនិយាយទាំងទឹកភ្នែកស្រក់ក្នុងបេះដូង។

«ចុះខ្ញុំ? ខ្ញុំស្រលាញ់នាងRose»

គេបន្ថែមហើយបន្ថែមទៀតធ្វើឱ្យស្រីស្អាតត្រូវតែបញ្ឈប់គេ៖

«លោកមានគូដណ្តឹងហើយ! ឪពុកក្មេកលោកនៅក្រៅនៅឡើយ! ឈប់គិតពីខ្ញុំទៅ! រឿងក្តីដែលលោកកំពុងធ្វើ វាមហាស្មុគ លោកទៅធ្វើទៅRoy ហើយប្រយ័ត្នខ្លួនផង ពួកប៉ូលិសអស់នោះរួមទាំងប៉ាក្មេករបស់លោកផង គ្មានបានការទេ!»

Roy លែងដៃពីចង្កេះនាង។ គេទាញកន្ត្រាក់ដៃនាងហើយសម្លឹងមុខយ៉ាងមុតៈ

«គិតថានាងដឹងរឿងប៉ូលិសច្រើនពេកហើយRose! នាងជាអ្នកយកការណ៍ឱ្យLorenzoឬនាងធ្វើការឱ្យមហាវីន?»

នាងនៅស្ងៀម គេនិយាយបន្ថែមទាំងពន្លែងដៃនារីនេះ៖

«នាងខ្លួនឯងហ្នឹងហើយដែលគួរប្រយ័ត្នខ្លួន! លេងភ្លើងច្រើន ក្រែងរលាក!»

គេចាកចេញពីបន្ទប់ហើយបិទទ្វារគ្រាំ....

នារីនេះឈរទ្រឹងស្ងាត់ជាមួយកែវភ្នែកពិចារណាស៊ីជម្រៅ...

វគ្គ អន្ទាក់មួយហើយអន្ទាក់មួយទៀត

«ម៉េចមិនឃើញចិត្រា?»

Royចូលមក ដល់ក្នុងឡានអង្គុយក្បែរលោកឱត សាម៉ុន ដែលកំពុងរង់ចាំនៅបាំងខាងក្រោយ។

គេចូលដល់ភ្លាមសួរតែកុងឡានទាំងមុខស្មើ។

លោកឱត សាម៉ុនឆ្លើយភ្លែត៖

«គេទទួលរឿងឯកមាននិងផានូ! មិនបានមកទេ!»

«ពីរនាក់នោះនៅតែគ្មានដំណឹង?»

«ពូមិនទាន់បានសួរគេទេ!»

Royងាកមកអោនគោរពអនាគតឪពុកក្មេកព្រមពេលដែលឡានបញ្ឆេះចេញដំណើរ។ ឡានប៉ូលិសពីរទៀត បោលតាមបន្តមកពីក្រោយ។

សភាពការណ៍ហាក់តែជ្រៅទៅៗ កម្សោយរបស់សមត្ថកិច្ចកាន់តែត្រូវបានមហាជនមើលឃើញ ។ រហូតដល់ពេលនេះ អ្នកណានៅពីក្រោយការបាត់ខ្លួន របស់ស្រីៗនៅតែរាវម្នុលក្នុងបាតសមុទ្រ។

ការចាប់ខ្លួនLorenzoក៏ពុំមែនជាគោលដៅបញ្ចប់រឿងដែរ ព្រោះថាប៉ូលិសជំនាញទាំងទ្វេដឹងស្រាប់ហើយ តារាសប្បុរសនោះគ្មានភាគរយច្រើនជាអ្នកពាក់ព័ន្ធធំក្នុងសំណុំរឿងនេះដូចដែលអ្វីពួកគេកំពុងលាបពណ៌ឡើយ។

ជំនួយការដេវីដគឺជាជនសង្ស័យសំខាន់ជាងគេមកដល់វេលានេះ។

សំខាន់ទីមួយគឺ គេជាមនុស្សរបស់មហាវីន តែបែរជាសម្លាប់មហាវីន ហើយឆ្លើយដាក់ Lorenzo? គេធ្វើដើម្បីអ្វីហើយព្រោះហេតុផលអ្វី?

សម្ដីRoseលាន់មកក្នុងការចងចាំដ៏ឈឺចាប់របស់គេ«....រឿងក្ដីដែលលោកកំពុងធ្វើ វាមហាស្មុគ លោកទៅធ្វើទៅRoy ហើយប្រយ័ត្នខ្លួនផង ពួកប៉ូលិសអស់នោះរួមទាំងប៉ាក្មេករបស់លោកផង គ្មានបានការទេ!»

Royធ្វើមុខក្រញូវព្រោះត្រូវស្ដាយរូបភាពតួអង្គតារាសប្បុរសដែលគួរឱ្យច្រណែននោះ មកតាមរុកកួនបេះដូង។ គេលូកយកឯកសារកម្រាស់ប្រមាណមួយអ៊ីញ ដែលបង្កប់នូវប្រវត្តិរូប Printនិងរូបថតមួយ រៀបចំដោយភ្នាក់ងារស៊ើបការនាយកដ្ឋានចារកិច្ចនិង ក្រុមស៊ើបការណ៍ឯកជនមួយនៅទៀតដែលគេបានទាក់ទងគ្នា ។

វាជាការងារងាយស្រួលដោយពិនិត្យមើលអ្នកដែលលៀនកន្ទុយមក ប៉ុន្តែមេក្លោងមែនទែនសូម្បីស្រីឬប្រុសតើត្រូវរង់ចាំដល់ភាគចុងក្រោយ?

នាយប៉ូលិសជាន់ខ្ពស់ មិនសូវចូលចិត្តអត្តចរិតអនាគតកូនប្រសាប៉ុន្មានទេ។ គេនេះមើលទៅពូកែយកគាប់គួរជានិច្ចនៅនឹងមុខគាត់ ហើយសម្រាប់កិច្ចពិភាក្សាការងារRoyនៅតែពុំមែនមនុស្សទីមួយដែលគាត់គិតដល់ឡើយ។

ទោះយ៉ាងណាពេលនេះ គាត់ហាក់ដូរចរិត។ លោកឱតសាម៉ុនចាប់ផ្ដើមនិយាយចេញមកនូវរឿងមួយចំនួនធំ៖

«ដំបូងចាប់ស្រីៗលាក់ !ក្រោយមកលែងវិញ! មកចាប់អមរាជាព្រោះចង់ឱ្យយើងចាប់អាចោរបីបួននាក់នោះ នឹងអាលវាបានឆ្លើយដាក់lorenzo! ចាប់ខ្លួនឯកមាននិងផានូ! គោលដៅវាជាស្អី? »

Royញាក់ភ្នែកដាក់គាត់ព្រោះមិនទុកចិត្តអ្នកបើកបរដែលនៅស្ងៀមស្ងាត់នាបាំងខាងមុខ។ លោកឱតសាម៉ុនដកដង្ហើមធំ គាត់ដំឡើងសំឡេងឮជាងមុន៖

«ពូមិនបានណែនាំ! ផ្កាយមួយ ដួង ធីណា គាត់ផ្លាស់មកពីបាត់ដំបង! ថ្នាក់លើឱ្យគាត់មកជួយពូ!»

Royទើបនឹងដឹងថា ខ្លួនពិបាកចិត្តពេកចូលមកក្នុងរថយន្តទាំងមិនបានចាប់អារម្មណ៍នឹងតែកុងឡានសូម្បីតែបន្តិច។ ចុះទម្រាំរឿងក្តីដ៏ចាក់ឫស ធ្វើម៉េចនឹងគិតឃើញងាយៗ?

«សូមគោរពស្នងការRoy!»

Royប្រញាប់ប្រញាល់គួរសម៖

«ខ្ញុំឮល្បីឈ្មោះពូនៅព្រហ្មទណ្ឌខេត្តតាំងពីខ្ញុំនៅរៀន! ខ្ញុំសូមគោរព!»

គេងាកមករកឌិតសាម៉ុន ព្រោះច្បាស់ក្នុងចិត្តថាឧត្តមសេនីយ៍នេះទុកអ្នកបើកឡាននៅខាងមុខជាគ្នាឯងក្នុងប្រតិបត្តិការនេះទៅហើយ។

គេចាប់ផ្តើមនិយាយ៖

«មិញពាក្យសម្តីពូមានមួយឃ្លានិយាយថា ដំបូងចាប់ស្រីៗលាក់! ក្រោយមកលែងវិញ?»

ឌិត សាម៉ុនឆ្លើយផ្ទួង៖

«អ្នកកាងសាលាឈុនរាជ ត្រូវគេវាយសន្លប់ហើយដឹងខ្លួនឡើងនៅល្ហាងនោះបាត់ទៅហើយ! គេមានចេតនាឱ្យឈុនរាជដោះលែងស្រីៗអស់នោះ!»

Royរភ្នែកគិតចុះឡើង។

«ពិបាកបំផុតគឺគ្រួសារអ្នកមានទាំងនោះមិនទាន់ព្រមឱ្យយើងជួបជាមួយកូនៗពួកគេសោះ! អត់តែម្តង!»

គាត់និយាយទាំងសៅហ្មង។ តាមថាអ្នកបាត់ខ្លួនទាំងបួនជាសាក្សីសំខាន់ក្នុងដំណើរការនេះ ប៉ុន្តែគាត់ក៏ដឹងដែរថាសំអាងលើភាពទោមនស្សជាមួយការងារប៉ូលិសនិងអំណាចរបស់គ្រួសារពួកគេចង់ជួបពួកនាងតទល់ក្រែងតែមិនងាយស្រួល។

«នៅនឹងកន្លែងយើងមានការសាកសួរខ្លះ! ខ្ញុំចង់និយាយពីក្រមុំៗទាំងបួនដែលត្រូវគេចាប់ទៅ! ខាងកូនចៅខ្ញុំកំពុងតែប្រមូល យូរបំផុតល្ងាចនេះយើងបានមើលវាហើយ!»

«មេពិធីការនោះ អាចជាសាក្សីគ្រាន់បើដែរទេ?»

សំណួររបស់គាត់ធ្វើឱ្យRoyមានអារម្មណ៍ថាជាឃ្លាឌីដង? ឬមកពីខ្លួនឯងមានចំណងបេះដូងលើនារីនោះបានជាគេតែងតែមានខ្លួនរាល់ពេលឮអ្នកណានិយាយអំពីRose?

Royខំប្រឹងលាក់កំបាំងមនោសញ្ចេតនាផ្លូវចិត្តហើយនិយាយៈ

«Roseត្រូវចាប់ក្រោយគេ បានន័យថា នាងនៅកន្លែងនោះមិនយូរទេស្មើអ្នកផ្សេងទេ! ហើយពេលនេះស្មារតីគេក៏នៅមិនទាន់នឹងននៅឡើយ! គេតែងតែភ័យហើយមិននិយាយរាល់ពេលខ្ញុំសួរ»

«ពួកលោកជិតដិតគ្នា?»

«បាទ!»

គេឆ្លើយភ្លាមព្រោះមិនអាចលាក់កំបាំងរឿងនេះនៅចំពោះមុខប៉ូលិសចំណាស់ដែលពេញដោយបទពិសោធន៍ឡើយ។

«ខ្ញុំទើបនឹងដឹងគេជាមនុស្សដែលខ្ញុំធ្លាប់ស្គាល់នៅឡុងដុងយូរមកហើយ! ពីមុនគេរៀននៅ Menchester »

បុរសចំណាស់រវេក្នែកគិតចុះឡើងហើយបោះសំណួរបន្ថែមៈ

«Menchester? ក្រែងជំនាញគេជាពិធីការ fashion ????»

«បាទ! នេះជារឿងក្រោយ! ពីមុនគេនៅ Menchester ខ្ញុំទៅលេងពូមួយនៅទីនោះ គេស្នាក់នៅផ្ទះពូ ខ្ញុំ ជួលបន្ទប់ផ្ទះគាត់ កាលណោះគេនៅក្មេងណាស់!»

រថយន្តបត់ចង្កូតចូលច្រកគេហដ្ឋានតារាសប្បុរសសាជាថ្មី។

«ដល់ហើយ!»

ផ្កាយមួយនៅខាងមុខពោលប្រាប់អ្នកជិះក្រោយ។ តាមកញ្ចក់ឡាន Roy សម្លឹងឃើញប៉ូលិសពីរឡានទៀតមកដល់ដង្ហែជាជួរ។

ឱត សាម៉ុននិយាយបន្ថែមៈ

«ខ្លាចតែគោលដៅវា មិនមែនអាណិកជនម្នាក់នេះ»

សម្ដីគាត់ធ្វើឱ្យRoyយកទៅភ្ជាប់ជាមួយឃ្លាទាំងឡាយមុននេះ «ដំបូងចាប់ស្រីៗលាក់! ក្រោយមកលែងវិញ! មកចាប់អមរាជា ព្រោះចង់ឱ្យយើងចាប់អាចោរបីបួននាក់នោះ នឹងអាលវាបានឆ្លើយដាក់lorenzo! ចាប់ខ្លួនឯកមាននិងផានូ! គោលដៅវាជាស្អី? »

«វាប្រើយើងឱ្យចាប់Lorenzoធ្វើអី?»

«វាទំនងជាលេងយើង! វាចង់យកប៉ូលិសមកលេងសើច!»

គាត់និយាយមួយៗទាំងសម្លឹងតាមកញ្ចក់ទៅបុរសអ្នកបើកឡាន មុនពេលសួរបន្ថែម៖

«ធីណាឯងបទពិសោធន៍ពេញខ្លួន! ឱ្យយោបល់ខ្លះមក!»

បុរសតែកុងក្រឡេកមករកRoyបន្តិចមុនពេលបញ្ចេញយោបល់៖

«បងសាម៉ុនសួរបានខ្ញុំហ៊ានលូកមាត់! យប់មិញខ្ញុំពិនិត្យរបាយការណ៍ពេញមួយយប់! ខ្ញុំឃើញសញ្ញាខ្លះ!»

«ស្អីទៅ?»

«អាណិកជននេះជាកូនអុកធំមួយ! ហើយគេចង់វាយអ្នកដែលស្រលាញ់អុកមួយនេះ»

«យើងគួរធ្វើម៉េចបន្តិចទៀតនេះធីណា?»

គាត់ញញឹមហើយនិយាយតប៖

«រកមើលថា អ្នកណាខ្លះដែលចេញមុខការពារកូនអុកនេះ! យើងនឹងដឹងថាសត្រូវពួកគេជាអ្នកណា!»

«ល្អណាស់ធីណា!»

គាត់និយាយខ្លីៗស្របពេលឡានឈប់ងឹត។

Royអោនមុខ ។ សក្តិលើស្មាគេនឹងបទពិសោធន៍របស់ម្នាក់នៅចំពោះមុខពិតជារឿងពិបាកធ្វើមិនដឹងមិនឮ។

«ស្នងការRoy កុំឱ្យមនុស្សស្រីនោះចេញពីផ្ទះលោក!»

ផ្កាយមួយនិយាយបន្ថែម។

«Rose?»

ឥឡូវនេះគ្មានអ្នកណាឆ្លើយតបសំណួរនាយទេ។ ដើងចាស់ឱិត សាម៉ុនបានរុញទ្វារចុះជាចេតនាបញ្ឈប់ការសន្ទនារបស់ពួកគេ។

ឥឡូវនេះ ការងារចំពោះមុខគឺនាំLorenzoទៅប៉ុស្តិ៍តាមសេណារីយោរបស់ពួកមនុស្សបិទមុខ។

គេអាចមានភាពជឿជាក់តិចតួចថាខ្លួនឯងបានយល់ អស់ពីអ្វីដែលចាស់ៗអស់នេះទើបនឹងជជែកគ្នា។

«មករកពីណាទាន!»

សន្តិសុខស្ទុះមកសួរ ។

«ជៀសផ្លូវទៅ!»

គាត់និយាយខ្លីៗដោយទឹកមុខមាំធ្វើឱ្យសន្តិសុខថយទៅម្ខាងទាំងដៀងភ្នែកទៅរករានហាលនៅជាន់ខាងលើ។

Royឃើញស្រមោលវឌ្ឍនៈនៅទីនោះ។

ស្គាល់ហើយថាជាជំនួយការដ៏អន្ទះសាររបស់អាណិកជនដែលលើកមុនងាកចង់ទូរសព្ទរកជំនួយ.....

ពួកគេចូលមកដល់បន្ទប់ទទួលភ្ញៀវពេលដែលអ្នកយាមកាមផ្ទះពីរនាក់ទៀតរត់ចេញថយទៅម្ខាងមិនហ៊ានទៅទើសមុខប៉ូលិស។

«ចៅហ្វាយខ្ញុំអត់នៅទេលោកនាយ!»

ឱិត សាម៉ុន ងើបមុខសម្លឹងទៅជំនួយការដែលថ្ងៃមុនត្រុនៗថ្ងៃនេះរឹងមាំ។ គេនោះដើរចុះមកពីជណ្តើរមួយៗ ស្របពេលភ្នែកបុរសចំណាស់ ដៀងមើលគេគ្រប់កន្លែងពីលើដល់ក្រោម។

«ចែកជាបីក្រុម Royដឹកនាំផែកក្នុងផ្ទះ !»

«លោកគ្មានសិទ្ធិទេ!»

វឌ្ឍនៈនិយាយទាំងខឹងញ័រមាត់តែស្នងការRoyលើកក្រដាសមួយផ្ទាំងបង្ហាញនៅមុខគេរហ័ស ស្មើនឹងឱ្យគេចុកមាត់បាន.....

«ដីកានេះគ្រប់អត់?»

គេសួរខ្មី ចំណែកភ្នែកជំនួយការវឌ្ឍនៈកាន់តែខ្មីជាង.....គេមិននិយាយអ្វីច្រើន ដកភ្នែកចេញពីក្រដាសនេះហើយសម្លឹងមកឱិត សាម៉ុនដូចចង់ប្រាប់ភាសាសម្ងាត់ថា៖

«លោកឯងមកយឺតហើយ!»

ឱិត សាម៉ុនរក្សាទឹកមុខស្មើដូចដែលគាត់ធ្លាប់ប្រកាន់យកហើយបន្តបញ្ជា៖

«ធីណា !»

«បាទទាន!»

«នាំមួយក្រុមទៀត ទៅទ្វារក្រោយ!»

ភាគទី៣៦

ឧត្តមសេនីយ៍ ឱិតសាម៉ុនដៀងភ្នែកមករកនាយជំនួយការម្នាក់នេះ។ គាត់សួរមួយៗទាំងអង្កេតជាប់លើទឹកមុខរបស់គេ៖

«ចៅហ្វាយលោកទៅណា?»

គេគ្រវីក្បាលហើយឆ្លើយវាហី៖

«គាត់មិនទម្លាប់និយាយប្រាប់អ្នកបម្រើដូចពួកខ្ញុំ ពីរឿងទៅណាមកណាទេទាន!»

ឱិត សាម៉ុនងាកឱ្យកូនចៅម្នាក់ផ្សេង ដែលនៅឈរក្បែរទ្វារហើយដាក់បទបញ្ជាខ្លី៖

«ខលទៅសុំរបាយការណ៍ពីប្រលានយន្តហោះ!»

«បាទទាន!»

សាជាថ្មីគាត់ងាកមករកវឌ្ឍនៈ។ បុរសនេះនៅរក្សាទឹកមុខស្មើដូចមិនខ្វល់ខ្វាយនឹងសកម្មភាពសមត្ថកិច្ច ប៉ុន្តែសម្រាប់ប៉ូលិសចំណាស់របស់យើងឯណោះវិញ សម្លឹងតែកែវភ្នែកគេក៏គាត់អាចដឹងបានពីរឿង ផុលរមាស់ ដែលកំពុងតែរត់ជ្រួលក្នុងបេះដូងគេបានបាត់ទៅហើយ។

ឱិត សាម៉ុនបញ្ជាបន្ថែមទៀង ក្នុងទឹកមុខធម្មតា៖

«ចំណែកម្នាក់ជំនួយការនេះ ក៏ត្រូវនាំខ្លួនទៅសាកសួរនៅស្នងការ!»

វឌ្ឍនៈទម្លាក់ភ្នែក ពេលដឹងថាខ្លួនកំពុងត្រូវដើរចូលរូងខ្លាជំនួសចៅហ្វាយ។ គេនៅតែមិនមាត់កអ្វី ទុកឱ្យបុរសចំណាស់ដើរចុះឡើងត្រួតពិនិត្យជុំវិញលំនៅឋាន។

«អត់ឃើញគេទាន!»

មនុស្សក្រោមបង្គាប់រាយការណ៍ពាក្យដដែលនេះមកពីគ្រប់គោលដៅក្នុងផ្ទះ។ ឧត្តមសេនីយ៍ងើបមុខសាជាថ្មីហើយដើរត្រុកៗមកក្បែរជំនួយការវឌ្ឍនៈ។

បុរសនេះរក្សាទឹកមុខស្មើផង ទោះបីចិត្តគេកំពុងប្រុងប្រយ័ត្នជាខ្លាំងចំពោះ ដំណើរសំដៅមកមួយៗរបស់ប៉ូលិសចំណាស់។

ដៃលោកឱិត សាម៉ុនដាក់ធ្ងន់ភឹបមកលើស្មាគេ បង្ខំវឌ្ឍនៈឱ្យងើបមុខមកសម្លឹងលោកនាយកផ្នែកព្រហ្មទណ្ឌស្របពេលដែលសំឡេងបុរសចំណាស់លាន់មកតិចៗ ចំពោះមុខ៖

«រឿងដែលលោកឯងធ្វើខុស ធ្ងន់ជាងគេក្នុងជីវិត ប្រហែលជាថ្ងៃនេះ!»

ឃើញគេសម្លឹងគាត់ភ្លឹះៗហាក់នៅមិនទាន់ស្តាប់យល់  គាត់ពន្លែងបន្ថែម៖

«លោកនឹងស្តាយក្រោយដែលមិនឱ្យចៅហ្វាយនៅជាមួយប៉ូលិស!»

វឌ្ឍនៈរក្សាការស្ងៀមស្ងាត់ហើយងាកមុខចេញឃឺតៗគេចពីការពិនិត្យរបស់នាយប៉ូលិស។

«បញ្ជូនគេទៅ!»

ឱិត សាម៉ុនស្រែកបញ្ជា។

វឌ្ឍនៈត្រូវបានរុញខ្នងចេញមកក្រៅផ្ទះតាមទ្វារខាងក្រោយ។

ចេញមកដល់ក្រៅគេឃើញឡានដែលខ្លួនបានបញ្ជាឱ្យបញ្ជូននាយចៅហ្វាយចេញទៅពេលនេះនៅចតចោលជ្រងោដូចដើម ឯអ្នកបើកក៏កំពុងអង្គុយស្ងៀមក្នុងឡានសម្លឹងមកក្រុមប៉ូលិសដោយនៅងឿងឆ្ងល់។

«លោកប្រុសតូចជិះឡានអ្នកណាទៅ?»

វឌ្ឍនៈដណ្ដឹងសួរខ្លួនឯងទាំងស្រយុតចិត្ត។

វគ្គ ការសួរចម្លើយ

វឌ្ឍនៈធ្លាប់បានគិតពីស្ថានភាព អាក្រក់នៃការសួរចម្លើយរបស់ប៉ូលិសខ្មែរតាមការស្រមៃផ្ទាល់ខ្លួន និង ពាក្យចចាមអារ៉ាមនានា។ ប៉ុន្តែពេលនេះភាពច្រាស់ច្រាល់នៃការគិតអំពីសុវត្ថិភាពរបស់ចៅហ្វាយក្មេងបានគ្របដណ្ដប់ពីការគិតអំពីស្ថានភាពផ្ទាល់ខ្លួន។

គេក្រឡេកពិនិត្យមើលជុំវិញទីតាំងដែលខ្លួនកំពុងអង្គុយ។ វាបន្ទប់តូចមួយ មានភ្លើងបំភ្លឺ និងកៅអីពីរបីជុំវិញតុឈើចាស់រាងទ្រវែង។

ទោះយ៉ាងណាបន្ទប់នេះមិនមានបរិយាកាសអាក្រក់ដូចដែលគេធ្លាប់បានគិតពីមុនមកនោះទេ។

បញ្ហាសំខាន់ក្នុងពេលនេះគឺថា តើប៉ូលិសទាំងពីរដែលកំពុងអង្គុយនៅក្នុងបន្ទប់នេះ អាចទុកចិត្តបានកម្រិតណា?

តារាងសង្ខេបការងារបិទព្យួរលើជញ្ជាំង រលឹកឡើងវិញពីស្ថានភាពពិតរស់ខ្លួនក្នុងពេលនេះឱ្យផ្ទង់លើសកម្មភាពមួយថា តើអ្វីខ្លះត្រូវនិយាយ និងអ្វីខ្លះទៀតត្រូវលាក់។

ប៉ុន្តែតើអាចលាក់បានដែរអត់?

«លោកមកភ្នំពេញតាំងពីពេលណា?»

គេមីងមាំងងើបមុខសម្លឹងម្ចាស់សំណួរ។ ស្នងការRoyក្រពាត់ដៃដូច្នេះ អ្នកសួរគឺឱត សាម៉ុន។

«ពេលណា?»

ប៉ូលិសសួរសង្ខេពបែបនេះ? រកពេលដកដង្ហើមមិនទាន់?

វឌ្ឍនៈលើកដៃនិយាយ៖

«ខ្ញុំមកភ្នំពេញច្រើនដងណាស់ ខ្ញុំនឹកភ្លាមៗ? នឹកម៉េចចេញ?»

«លើកចុងក្រោយ ដែលមកជាមួយLorenzo គឺលើកនេះ!»

«ថ្ងៃ២០ខែ មិថុនា!»

បុរសជំនួយការនេះ ឆ្លើយស្រពាប់ស្រពោន ។ គេដឹងថា កំណត់ត្រាចេញចូលមិនអាចកុហកអ្វីបានទាំងអស់ដូច្នេះ គេត្រៀមខ្លួនរង់ចាំដោះស្រាយជាមួយសំណួរបន្ទាប់។

«អ្វីទៅជាបំណងធំ ដែលគេមកភ្នំពេញលើកនេះ?»

«គេ»

គឺលោកប្រុសក្មេងដែលកំពុងគេចខ្លួន។ វឌ្ឍនៈដឹងតែគេធ្វើពើ ហើយនៅស្ងៀមរក្សាទឹកមុខដូចជាងឿងឆ្ងល់។

«កុំពន្យារពេល!»

ស្នងការRoyនិយាយដោយទឹកមុខស្មើ ប៉ុន្តែវឌ្ឍនៈរឹតតែមិនចាញ់សម្លុត។ ក្នុងអារម្មណ៍គេជាសម្ងាត់ គេដឹងថាស្នងការក្មេងម្នាក់នេះ មានអ្វីមួយអគតិចំពោះខ្លួនច្បាស់ណាស់តាមរយៈទឹកមុខ សម្តីសំដៅនិងកាយវិការរបស់គេ ប៉ុន្តែគ្មានអ្នកណាដឹងទេថាក្រៅពីបញ្ហាភារកិច្ច ស្នងការនេះថែមទាំងមានគំនិតប្រចណ្ឌស្ងាត់ៗទៅលើLorenzoផង។

វឌ្ឍនៈឆ្លើយដោយមិនញញើត៖

«លោកដែលនិយាយពីបំណងរបស់ខ្លួនឯងប្រាប់ទៅអ្នកបម្រើទេ?»

«កុំលេងស្មៀត! អាណិកជនត្បាញអាយនោះ មិនទុកឯងជាអ្នកបម្រើទេ!»

Royនិយាយដោយមុខក្រញូវ។ ហាក់មិនអស់ចិត្តគេបន្ថែម៖

«ត្រូវចាំរឿងមួយថា បើម្នាក់នោះមានរឿងអី លោកឯងនិងជាប់ពីបទសមគំនិតដូចគ្នា!»

ជំនួសឱ្យការប្រឈម និងអ្នកសួរ គេងាកទៅមើលជញ្ជាំងវិញ។

«ឆ្លើយមក!»

លោកឱតសាម៉ុនតឿនខ្លីធ្វើឱ្យវឌ្ឍនៈចាំបាច់ត្រូវឆ្លើយ៖

«គាត់មករកគូព្រេង!»

ឱត សាម៉ុនងាកទៅមើលRoyចំពេលចិញ្ចើមស្នងការលើកជាមួយអាការៈផ្ទុះចេញមហាចម្លល់....

នៅឯណោះវិញ បុរសដែលកំពុងត្រូវគេនិយាយដល់គ្រប់ទីកន្លែង កំពុងប្រញាប់ប្រញាល់ពិនិត្យផ្លូវដែលខ្លួនកំពុងធ្វើដំណើរ ព្រោះអ្វីមួយហាក់ខុសប្រក្រតី កើតមានក្នុងអារម្មណ៍នាយ។

អ្នកបើកបរ ដែលមួយកំណាត់ព្រឹកហើយ មិននិយាយអ្វីសោះ ធ្វើឱ្យLorenzoទទួលអារម្មណ៍ថា អ្វីមួយខុសៗធម្មតាកំពុងគ្របដណ្ដប់មកលើស្ថានភាពរបស់ខ្លួន។

ពន្លឺពណ៌ក្រហមនៃព្រះអាទិត្យហាក់បីដូចជាជ្រេរាលទៅលិច។ ទិដ្ឋភាពនៅខាងស្ដាំដៃ ដែលរត់ថយក្រោយខ្ញុំលែងជាទីក្រុងភ្នំពេញទៀតហើយ។

នៅចាំបានថា  ខ្លួនចាកចេញមកក្នុងសភាពប្រញិបប្រញាប់ ហើយវឌ្ឍនៈក៏នៅមិនទាន់បានប្រាប់គេនៅឡើយផងថា ទៅទិសដៅណា។

Lorenzo ឈប់គិតពីlaptopហើយ គេងាកទៅសួរសូហ្វ៊ីរ៖

«យើងទៅណាហ្នឹង?»

«ទៅខេត្ត!»

គេឆ្លើយខ្លីហាក់មិនចង់និយាយ តែបើគិតម្យ៉ាងទៀតគឺដូចជាប៊ូតុងដែលរង់ចាំឱ្យគេចុចនឹងអាលឆ្លើយ។

ដៃនាយរាវរកទូរសព្ទ ។គំនិតមួយគឺខលរកវឌ្ឍនៈ តែគំនិតមួយទៀត គិតពីស្ថានភាពនៅទីនោះ។

ប្រសិនបើ ទូរសព្ទរបស់វឌ្ឍនៈកំពុងស្ថិតក្នុងដៃប៉ូលិស គេនឹងអាចរកទីតាំងដែលខលទៅនេះបាន។

«ខ្ញុំគិតថា យើងគួរត្រៀមខ្លួនឱ្យល្អជាងនេះបង្ការពួកប៉ូលិស!»

គ្មានចម្លើយ .....

ប្រុសស្អាតជ្រួញចិញ្ចើម។មនុស្សល្ងង់យ៉ាងណាក៏គង់ដឹងថាខ្លួនឯងកំពុងស្ថិតក្នុងស្ថានភាពអ្វីដែរ។

«ឈប់ឡានទៅ!»

គេបញ្ជាតិចៗស្របពេលក្រឡេកទៅឃើញទូរសព្ទខ្លួនគ្មានសេវារលើង។

រហ័សដូចផ្លេកបន្ទោរ Lorenzo អង្គុយត្រង់ខ្លួនហើយពិនិត្យតួឡានមួយនេះ។ វាប្រាកដជាមានបង្កប់អ្វីម្យ៉ាងដែលអាចឱ្យសេវាខាងក្រៅលែងជ្រៀតចូលមកបាន មានន័យថារាល់ទំនាក់ទំនងតាមបណ្ដាញទូរសព្ទ internet នឹងត្រូវកាត់ផ្ដាច់។

ការអត់ធ្មត់បានមកដល់ព្រំដែនចុងក្រោយ។

គេលូកយកវត្ថុរឹងក្នុងសម្ពាយដែលវឌ្ឍនៈរៀបឱ្យមក ហើយភ្ជង់សំដៅ ក្បាលសូហ្វ័រ៖

«អញឱ្យឯងឈប់!»

ឡានឈប់ងឹត។

អាណិកជនរវើ្ភកសម្លឹងជុំវិញខ្លួន។

ដងផ្លូវលំនៅពីមុខនេះ មានពន្លឺថ្ងៃស្រអាប់ខ្មៅព្រោះជារុក្ខវិថីអមដោយរុក្ខាស៊ុបទ្រុប។ នេត្រាទាំងសងបញ្ឈប់នៅត្រង់កញ្ចក់ឡានខាងមុខដែលនៅលើនោះ កែវភ្នែកភ្លឹមុតរបស់អ្នកបើកឡានសម្លឹងមកនាយវិញដូចគ្នា។

ដៃLorenzoភ្ជង់គេកៀកជាងមុន។ មាត់នាយក៏បញ្ជាខ្សឹបៗ៖

«លើកដៃឡើង! កុំកម្រើក»

នៅលើដៃទាំងពីរដែលលើកឡើងលើ Lorenzo សម្លឹងឃើញខ្សែដៃ ពណ៌ខ្មៅក្បួចត្របាញ់ គួរឱ្យសង្ស័យ។ អាណិកជនបង្វិលក្បាលរបស់គេមកចំហៀងខាងស្តាំយឺតៗ ព្រោះចង់ឃើញមុខគេនេះឱ្យច្បាស់។

មាត់ក៏សួរក្នុងពេលដំណាលគ្នា៖

«អ្នកណាបញ្ជូនឯងមក?»

គេនោះបូញមាត់ទៅខាងមុខ។

នៅចម្ងាយប្រមាណតែ១០ម៉ែត្រគេសម្លឹងទៅត្រង់តាម របារកញ្ចក់ឡានក៏ឃើញមនុស្សប្រុសបួនប្រាំនាក់មាឌធំ និងកម្ពស់ខ្ពស់ដែលមានស្បែកស្រអាប់ៗ តម្រៀបគ្នាពីមុខម៉ូតូធំៗ។ Lorenzo ឃើញកាំភ្លើងលើដៃពួកគេ នាយទស្សន៍ទាយបានដោយខ្លួនឯងថា បើមិនអាចដោះស្រាយស្រួលបួលទេ គេអាចនឹងចោលឆ្អឹងនៅទីនេះ។

ផ្ទូងៗ....

ឡានស្រុញចុះ កង់វាបែកអស់ហើយគេដឹង។ ទោះគេបាញ់បំបែកសន្ទះក្បាលអាម្នាក់បើកបរនេះក៏មិនអាចគេចេញទៅណារួចដែរ គេដឹង។

«ពួកឯងត្រូវការស្អីអ្ហះ?»

អ្នកបើកបរនោះសើចកក្អៀក ។

Lorenzoសម្លុត៖

«ឱ្យតែអញកេះកៃ! ក្បាលអ្វែងនឹងខ្ទេច! »

«កេះទៅអ៊ីចឹង?»

គេអោនសម្លឹងកាំភ្លើងទាំងចិត្តរារែក ចំណែកអ្នកបើកឡានសើចក្អាកក្អាយ រុញទ្វារចាកចេញ។

ប៉ុន្មានវិនាទីនេះ បើមិនបាញ់កាំភ្លើងទៀតមានតែរង់ចាំសេចក្តីស្លាប់?

គេអត់ការដកដង្ហើមហើយកេះកៃបាញ់។

គ្រាប់កាំភ្លើងគ្មានទេ។

វាត្រូវបានដកចេញចោលតាំងពីពេលណាមកក៏មិនដឹង។

«មិនសមថា បងវឌ្ឍនៈក្បត់ខ្ញុំ?»

គេគិតភ្លាមៗ ហើយអស់សង្ឃឹមក្នុងការស្វែងរកដំណោះស្រាយគាប់ប្រសើរមួយសម្រាប់ខ្លួនឯងក្នុងពេលឥឡូវនេះ។

គេនៅភាំងក្រោមការសន្ទប់ជាប់ដោយគំនិតមន្ទិលសង្ស័យសោកស្ដាយ និងទ័លច្រក។ ទ្វារខាងស្ដាំរបើក....

គ្មានអ្វីក្រៅពីពួកអស់នោះចូលមកនាំខ្លួនចេញទៅនោះទេ គេគិតម្នាក់ឯងស្ងាត់ៗហើយនឹកឃើញដល់ឪពុកម្ដាយធម៌....

«កូនមិនលុះដំបូន្មាន នេះហើយជាលទ្ធផល! មនុស្សទាំងឡាយសុទ្ធតែជាឆ្កែចចក!»

គេពោលប្រាប់ខ្លួនឯងក្នុងសព្ទសំឡេងទាបទាំងទម្លាក់ចោលកាំភ្លើងពីដៃ។ មនុស្សអាក្រក់ដែលគេមិនស្គាល់មុខ បានលូកប្រអប់ដៃដ៏ធំមកច្បាមស្មានាំរាងកាយតារាសប្បុរសដ៏ល្បីក្នុងបេះដូងស្រីៗចេញមកក្រៅលើដងផ្លូវស្ងាត់ក្រោមភាពសោមនស្សរបស់គ្នាវាផ្សេងទៀត។

«អាមនុស្សនេះ មុខអ៊ីចឹងមិនសមលង្វង់ថ្នាក់ហ្នឹងទេវ៉ី?»

អាណិកជនត្រូវច្រានដួលទៅលើដី ហើយកាណុងកាំភ្លើងវែងភ្ជង់ផ្ទប់មកលើក្បាលគេ។

«យើងបានធ្វើអីពួកឯង?»

«មិនដឹង! តែឯងប្រហែលធ្វើឱ្យទើសចិត្តអ្នកមានដែលឱ្យលុយអញចាយ!»

ពួកនេះឆ្លើយឆ្លងព្រហើនពានពារមិនមានញញើតញញើមទំនងជាស្គាល់តំបន់នេះច្បាស់ ហើយទុកចិត្តប្រាកដណាស់ថា គេក្លាយជាសត្វចៀមកណ្ដាលហ្វូងចចកទៅហើយ។

«ត្រូវការលុយប៉ុន្មាននិយាយមក!»

គេនិយាយរួ តបតទៅនឹងក្រុមអន្ធពាល ទាំងមិនដឹងឡើយថាវាមានប្រសិទ្ធភាពកម្រិតណា ស្រាប់តែចុងកាណុងកាំភ្លើងបែររបូតចេញ ហើយដៃដដែលទាញរាងកាយនាយឡើង។

ម្នាក់ច្បាម Lorenzo ជាប់ ម្នាក់ទៀត ឈរមកចំពីមុខហើយសម្លឹងនាយចុះឡើង។

«ឆ្វើយ! គេមានមួយម៉ឺន អ្ហែងមានពីរម៉ឺនអត់?»

Lorenzo ដឹងថា ដង្ហើមរស់ឡើងវិញនៅជិតបង្កើយទោះបីជាក្នុងដៃខ្លួន គ្មានប្រាក់ច្រើនថ្នាក់នេះក្តី។នាយសម្លឹងទៅមនុស្សទាំងប្រាំដែលកំពុងតែផ្តោតមក។ កដៃពួកគេដូចគ្នាបេះបិទគឺមានពាក់ខ្សែចំណងម្នាក់មួយពណ៌ខ្មៅដូចគ្នា។

ពួកនេះទំនងជា មនុស្សរកស៊ីចាប់ចង។ មានក្រុមមានបក្ស និងមានចិត្តសាហាវស្គាល់តែលាភសក្ការប៉ុណ្ណោះ។

គេបញ្ជាទៅពួកអ្នកស្រេកឃ្លានប្រាក់៖

«ប្រាប់ឈ្មោះវាមក ឯងនឹងបានបីម៉ឺន!»

ម្នាក់នៅពីមុខគេ ញាក់គ្រាប់ភ្នែកចុះឡើងពេលឮទំហំទឹកលុយដែលអាណិកជនបង្អួត។ គេសម្លឹងនាយចុះឡើងមុនពេលនិយាយសម្លុត៖

«អ្ហែងបោកសុទ្ធ! បើអ្ហែងមានលុយមែនចាំបាច់ អីអ្ហែងទៅកុងរកស៊ីជាមួយគេឱ្យគេចាប់មកអ្ហ៎ា?»

«មហាវីន?»

គេនឹកក្នុងចិត្តទាំងភ្ញាក់ផ្អើលនឹងសៅហ្មង។ ថៅកែកន្ទាត់នោះដេកពេទ្យហើយ តែនៅមកបង្ករឿងអស់ទាំងនេះបានទៀត?

សន្សឹមៗ នាយអោន ដោះយក Rolex GMTដ៏មានតម្លៃ ពីដៃដែលកំពុងពាក់។

«វាមិនមែនជារបស់ក្លែងក្លាយទេ»

អ្នកនៅមុខគេផ្ទៀងផ្ទង់ ពិនិត្យហាក់ទុកពេលឱ្យអ្នកមួយដែលនៅក្រោយវា លូកដៃមកកន្ត្រាក់កាន់មើលជាមួយនិងការលោន់មាត់។

«Rolex »

ពួកនេះមិនមែនអ្នកជនបទទេ Lorenzoដឹង ហើយដៀងភ្នែកមួយត្រួសសម្លឹងពួកគេម្ដងម្នាក់។

ភាពស្រេកឃ្លានរបស់ពួកគេ កាន់តែធ្វើឱ្យនាយបានចិត្ត ។

អាណិកជននិយាយ៖

«របស់នេះមានតម្លៃយ៉ាងណាឯងគួរតែដឹងហើយ! តែបើចង់បានលុយទៀត ហុចទូរសព្ទមក!»

«អញមិនល្ងង់ឱ្យអ្នែងខលប៉ូលិសទេអាមោយ!»

គេនោះប្រកែកតែហាក់បីដូចជាចង់ខ្លះ ព្រោះដៃវាវរកទូរសព្ទទៅហើយ។ Lorenដឹងថា លុយជាអ្វីដែលពួកគេចង់បាន ទើបគេបន្ថែមទៀតភ្លាម៖

«កាំភ្លើងក្នុងដៃពួកឯងបាញ់ខ្ញុំពេលណាក៏បាន!»

«ម៉ោះកុំឱ្យយូរការ!»

ដៃម្នាក់ដែលនៅពីក្រោយគេហុចទូរសព្ទមកជ្រែកពួកអ្នកខាងមុខធ្វើឱ្យគ្នាវាងាកក្រោយទៅមើលម្ចាស់របស់មួយនេះព្រាត។

គេនោះហាក់ដឹងខ្លួនថាកំពុងរមូរពោះរឿងលុយម៉ឺនៗពេកបានជាកែទឹកមុខធ្វើជានិយាយបន្លប់៖

«អញគ្រាន់តែចង់ដឹងថា វានេះកុហកបានយូរប៉ុនណា!»

Lorenzoប្រើម្រាមទាំងពីររបស់នាយចុចប៊ូតុង ក្រោមការលើកកាំភ្លើងមកភ្ជង់គ្រប់ទិសទី។ ការវេរលុយតាមបណ្ដាញមកកាន់លេខទូរសព្ទដោយប្រើប្រាស់ប្រព័ន្ធធនាគារជាច្រើនតង់មិនចាំបាច់ទៅកាន់បញ្ជរវេរលុយ ជារឿងដែលពួកគេមិនធ្លាប់ដឹងមកពីមុនទេ ប៉ុន្តែវាបានកើតឡើងពិតមែនក្នុងពេលនេះ។

ការទទួលសារជាអក្សរ បានលោតមកដល់ពេលដែលLorenzoងើបមុខហើយប្រគល់ទូរសព្ទមកឱ្យពួកគេវិញ។

ម្នាក់ៗចំហមាត់ពេលឃើញចំនួនទឹកប្រាក់លើសារមិនធ្លាប់បានទទួល។

«ពិតអត់! អានេះឆ្កិនភ្នែកយើង! វាសរសេរសារក្លែងក្លាយបោកយើង!»

ភាគទី៣៧

ម្ចាស់ទូរសព្ទលាន់មាត់បែបនេះ ប៉ុន្តែភាពស្ញប់ស្ញែងកើតមានក្នុងកែវភ្នែករបស់គេ។ អាណិកជននិយាយតប៖

«អាចឱ្យលេខលើនេះទៅបងប្អូនទៅបើកលុយបាន!»

ពួកគេសម្លឹងមុខគ្នា។

ម្នាក់នៅពីមុខគេស៊ីញ៉ូឱ្យសញ្ញាគ្នាវា។ ឃើញដូច្នេះម្នាក់ដែលជាម្ចាស់ទូរសព្ទចាប់ផ្តើមទាក់ទងចេញ។ អ្នកដែលនៅសល់សម្លឹងLorenzoពីលើចុះក្រោម ពីក្រោមឡើងទៅលើ។

«អ្ហែងគិតម៉េច បើអញបានលុយហើយនៅតែមិនលែងឯង?»

«ពួកឯងនឹងលែងបានការងារល្អៗ បានថ្លៃខ្ពស់ៗយកទៅធ្វើទៀត!»

ពេលដែលបុរសលែងខ្លាចលែងភ័យព្រោះតែអំណាចទឹកលុយរបស់គេ ជនទាំងក្រុមនេះកាន់តែច្រាស់ច្រាល់រារែកសម្លឹងមុខគ្នាមិនដាច់ស្រេច។

Lorenzoនិយាយបន្ថែម៖

«ក្រែងសព្វបែបយ៉ាងគ្រាន់តែដើម្បីលុយតើហ្អី? បើពួកឯងយកអាកន្ទាត់នោះធ្វើមេកោយបាន ម៉េចមិនព្រមទទួលយកអ្នកដែលចាយលុយធំជាងផង?»

«ឆ្ងើយ! គ្មានអាណាម្នាក់ជាមេអញទាំងអស់មានលុយអញធ្វើ អត់លុយងាប់!»

ម្នាក់នៅពីចំហៀងនិយាយ ខាងឆ្វេងនិយាយទាំងងាកមុខដើរចេញ។ តែLorenzoដឹងថា គ្នាវាផ្សេងទៀត កំពុងតែត្រដរដំណឹងលុយ។

«បើអ្ហែងហ៊ានលេងប្ងូនសន្លឹក ដឹងគ្នាហើយអាក្អូនអ្ហា!»

ម្នាក់នៅមុខគេនិយាយហើយ ថយទៅអង្គុយលើក្បាលឡាន។

Lorenzoដើរតាមគេនោះតត្រុក ព្រោះដឹងថាមានតែម្នាក់នោះទេ ងាយស្រួលនិយាយគ្នាជាង គេ ។ឃើញអាណិកជនដើរមកតាម វានោះសម្លក់នាយហើយគំហកដាក់៖

«មិននៅឱ្យស្ងៀមមួយកន្លែង ក្រែងចុងកាំភ្លើងវាគ្មានភ្នែក!»

Lorenzoងាកសម្លឹងបីនាក់ទៀតដែលកំពុងប្រុងជើងការនៅឡើយ។ គេចាប់អារម្មណ៍ជាងគេតែតៃកុងឡានដែលកន្លងមក រហូតដល់ពេលនេះមិនឮហើបមាត់អ្វីមួយម៉ាត់ណា។

គេសួរតិចៗទៅកាន់អ្នកដែលនៅលើក្បាលឡាន៖

«ខ្ញុំចង់ដឹងថាឡាននេះដាក់អីបានជាទូរសព្ទខ្ញុំខលមិនចេញ ហើយជំនួយការខ្ញុំជាអ្នកធ្វើ?»

ម្នាក់នោះនៅស្ងៀមបិទមាត់ដូចគេចុក។ អាណិកជនគួរតែដឹងថាការសម្ងាត់ជាក្បួនដ៏សំខាន់

នៃមុខរបររបស់ពួកគេ។ ពួកមនុស្សប្រភេទនេះបើមិនត្រូវជំនាញសួររបស់សមត្ថកិច្ចគឺមិនព្រមហើបមាត់ឆ្លើយនោះឡើយ កុំថាឡើយត្រឹមនាយជាមនុស្សមិនទាន់រួចពីស្លាប់១០០ភាគរយបែបនេះ។

«អាក្រម៉ាប់នោះ មានទំនាក់ទំនងជាមួយជំនួយការខ្ញុំ?»

គេសួរស្ទាបស្ទង់បន្ថែមក្នុងសូរសំឡេងទាបទំនងតែឮបានពីរនាក់ដឹងអីគូសន្ទនាតបវិញឮៗ ៖

«មើលអាម៉េចថាអាម្នាក់ហ្នឹងផាត់?»

Lorenzoងើបមុខមកវិញធ្វើឱ្យអ្នកដែលជ្រុលមាត់ហាក់ដឹងខ្លួនពីការឆ្លោយ។ យ៉ាងហោចណាស់អាណិកជនអាចចាប់ថ្នាក់បានជាស្រេចថា អ្នកដែលបញ្ជាពួកទាំងនេះពុំមែនជាមហារីនទេ។

អ្នកនៅក្បាលឡានលូកដៃចង្អុលមុខនាយ ទាំងមួហ្មង ហើយពោលពាក្យទ្រគោះ៖

«ឈប់មាត់ប៉ប៉ែះរ៉ី!»

ម្ចាស់ទូរសព្ទរត់ត្រឡប់មកវិញ។

Lorenzoដឹងពីលទ្ធផលជាមុនទៅហើយម្ល៉េះហើយ នាយគ្មានអ្វីត្រូវភ្ញាក់ផ្អើលទេ។ ទោះបីជាយ៉ាងណា ពួកគេទាំងប្រាំរត់ទៅរកគ្នាហើយពិគ្រោះទាំងអំណរ។

ឆ្លៀតពេលនេះអាណិកជនរវេភ្នែកសម្លឹងមើលជុំវិញខ្លួន។

មេឃជិតងងឹតមែនទែនហើយ។

គេទើបនឹងចាប់អារម្មណ៍ថាទីនេះត្រជាក់ទៅៗ។ វាមិនទំនងថានៅក្បែរភូមិករទេ គួរតែនៅក្បែរព្រៃ។

មនុស្សម្នាក់វិលមកវិញជាមួយទឹកមុខស្រស់ស្រាយទោះជាមិនមានស្នាមញញឹម។

«ទៅបាន! តែទៅឱ្យឆ្ងាយប្រយ័ត្នគេរកឃើញ!»

គេឆ្លៀតនិយាយភ្លាម៖

«ឯងមិនទាន់ប្រាប់ខ្ញុំទេ ថាអ្នកបញ្ជាឈ្មោះអី!»

«កុំរញ៉េរញ៉ៃច្រើន!»

គេនោះគំហកខ្លីហើយលូកដក កាំភ្លើងខ្លីមួយពីចង្កេះខោហុចមកឱ្យ។

«អំណោយហ្វ្រី! ជួបគ្នាលើកក្រោយកុំភ្លេចឱ្យលុយចាយ!»

វាជាកាំភ្លើងដ៏ចាស់មួយតែធ្ងន់កណ្ដុក។

អាណិកជនទទួលមកកាន់ទាំងរងើរងើ។

«តោះកុំនៅយូរ!»

ពួកគេមានសភាពដូចជាបានលុយហើយខ្លាចមានគេមកទាន់ ម្នាក់ប្រញាប់ទៅតែម្នាក់ទៀតស្ទុះចូលមកស្ទាបហោប៉ៅនាយរាវរកសព្វបែបយ៉ាងប្រមូលយកទៅអស់មិនសល់សូម្បីតែកន្សែងជូតសម្បោរ។

ពួកវាកេះគ្នាបម្រុងចាកចេញ តែអាណិកជននៅតែមិនអស់ចិត្ត។

គេក៏ចាំបាច់ថែរក្សាអាយុជីវិតជាមុនសិនដែរ បានជាទាញដៃម្នាក់ក្រោយគេនោះមកវិញហើយអង្វរ៖

«សុំទូរសព្ទវិញមក! ខ្ញុំមិនស្គាល់ផ្លូវទេ!»

«កុំនៅញ៉ុមញ៉ុមទៅខាងត្បូងនោះទៅ! រត់ឱ្យឆ្ងាយទៅ! ផ្លូវនោះឧស្សាហ៍មានគេចេញចូលច្រើន!»

មិនថាមានអ្វីកើតឡើងនោះទេ គេដឹងថា ពួកនេះមិនព្រមឱ្យគេវិលចូលទៅក្នុងឡានយករបស់ឡើយ។

គ្រោះថ្នាក់នៅតែស្រមោលអន្ទោលតាមប្រាណ ព្រោះថាឯកសារសំខាន់នៅទីនោះទាំងអស់។

ស្នូររថយន្តបោលមកពីចម្ងាយ ។

ពួកគេទាំងប្រាំវិលមកក្នុងសភាពប្រុងជើងការវិញ។ អ្វីដែលអាណិកជនទើបនឹងរួចជីវិតត្រូវធ្វើក្នុងពេលនេះគឺដកថយទៅតាមទិសដែលគេចង្អុលប្រាប់។

គេដើរបណ្ដើររត់បណ្ដើរក្រោមផ្សែងស្រអាប់ងងឹតទៅៗ....

ដើរសឹងរលេះជើងហើយនៅតែគ្មានឃើញស្រមោលកង់មួយកុំថាឡើយម៉ូតូ។

«ពួកនេះមានចេតនាបញ្ឆោតយើងឱ្យទៅដេកដាច់ពោះក្នុងព្រៃ?»

គេគិតទាំងទោមនស្ស គិតហើយគិតទៀតពីជោគវាសនាចំពោះមុខ និងសមាសភាពអ្នកដែលបង្កបញ្ហានេះឡើងចំពោះគេ។

ស្នូរគ្រាប់កាំភ្លើងលាន់មករប៉េះរប៉ោះ.....

វាជាការដាស់អារម្មណ៍ប្រកបដោយប្រសិទ្ធភាពថា ពួកមនុស្សទាំងប្រាំទំនងជាពើបប្រទះនឹងអ្នកដែលទើបមកដល់ហើយឆាកប្រយុទ្ធបានកើតមាន?

មិនថារឿងហេតុរបៀបណាទេ គេចាប់ផ្ដើមបង្កើនល្បឿនរត់។ មិនបានប៉ុន្មានផង រាងកាយបុរសសង្ហា ដែលមិនថ្នឹកនឹងការរត់កាត់ភាពងងឹតបានភ្លាត់ជំហរដួលទៅលើដី។ ចៃដន្យទីនេះពុំមែនជាដីរាបស្មើម្ល៉ោះហើយប្រុសស្អាតចាប់ផ្ដើមរមៀលធ្លាក់ដោយមិនដឹងទីដៅ។

វគ្គ បុប្ផាជាយព្រៃ

ថ្ងៃលិចទាំងស្រុងហើយ ប៉ុន្តែនាងទើបនឹងចាប់ផ្ដើម ចម្អិនអាហារ។

ទីនេះមិនមែនជា «ផ្ទះអនាគត» ដែលនៅក្បែរព្រៃទេ ប៉ុន្តែជាផ្ទះរបស់ស្រីតូចឈ្មោះសន្យាប្អូនធម៌របស់បងឈុនរាជ។

ដណ្ដាំអាហារផង បើកបង្អួចផ្ទះបាយផង ដូច្នេះនាងអាចនឹងរីករាយសម្លឹង ភាពស្រស់ស្រាយនៃថ្ងៃទេសភាពស្រមោលទិនករសេសសល់ លើជម្រាលបៃតងលឿង។

រំពេចនោះ នាងពិតជាមើលឃើញមនុស្សម្នាក់រត់ ហើយក្រោយមកគេនោះដួលស្រុញបាត់។ ទោះបីអ្វីៗហាក់មិនច្បាស់ តែនាងចង់ដឹងណាស់ថានោះជា អ្វីទៅ?

នាងរត់សំដៅគោលដៅហើយចុះតាមជម្រាលភ្នំដែលខ្លួនធ្លាប់ស្គាល់យ៉ាងស្និទ្ធ។

«មនុស្សធ្លាក់មែនហើយតែគេនៅឯណា?»

នាងគិតហើយក៏ដំឡើងសំឡេងស្រែកសួរៈ

«មានអ្នកណានៅក្រោមអត់ហ្នឹង?»

បរិយាកាសហាក់ព្រងើយកន្តើយនឹងការស្រែកហៅរបស់នាង ឮតែសំឡេងខ្លួនឯងខ្ទរត្រឡប់មកវិញល្វើយៗ។

ពិនិត្យសព្វគ្រប់កើត លិច ជើង ត្បូងមិនឃើញមានអ្វីប្លែក ស្រីតូចបែរឃើតៗត្រឡប់ក្រោយបម្រុងនឹងវិលទៅវិញ ព្រោះរាត្រីកាលក៏ត្រៀមនឹងពន្លិចទីនេះទៅក្នុងភពងងឹត តែនៅពេលដែលនាង

ដើរបានប៉ុន្មានជំហាន អ្វីមួយជាប់ទើររវិចលើមែកឈើ បង្ខំនាងឱ្យភ្ញាក់ព្រើត។

ទីនេះមិនដែលមានអ្នកណាមកភ្លេចអាវអ្វីនឹងមែកឈើថ្មើរណេះ?

ណាមួយមើលពីចម្ងាយ ដូចជាមិនមែនតួអាវទាំងស្រុងផងបណ្ដាលឱ្យនាងមានការសង្ស័យជាខ្លាំង។

ស្រីតូចរត់សំដៅទៅក្បែរប៉ប្រះព្រៃ។ នៅក្រោមភាពងងឹត៩០ភាគរយនៃអន្ធការ អ្វីមួយខ្មៅស្នុងពិតជាសំងំច្រងាង នៅទីនោះ ប្រមាណជា១០ម៉ែត្រប៉ុណ្ណោះពីមុខនាង។

រាងជាមនុស្សដេក ហើយសន្យាប្រាកដចិត្តណាស់ថា ជាមនុស្សដែលនាងបានឃើញធ្លាក់។

ស្រីប្រមក់ដើរសន្សឹមៗ ចូលទៅ.....

« នែ៎! ពូ? ពូ?»

គ្មានចម្លើយ តែគេហាក់កម្រើកខ្លួនលាយសំឡេងថ្ងូរ។ ចិត្តនាងអាណិតអាសូរច្រើនជាងភ័យរន្ធត់។សន្យាដឹងថា បុរសពុំមែនជាអ្នកភូមិ ដែលខ្លួនធ្លាប់ឃើញ ហើយគេប្រាកដជារត់គេចពីអ្វីមួយមិនស្គាល់ទិសតំបន់បានជាត្រូវដួលធ្លាក់សល់សំណល់ដៃអាវរហែក បក់រវិចកៀងជាប់នឹងប្រកៀកឈើក្បែររាងកាយ។

«ពូឯងមានរឿងអី!»

ចម្លែកណាស់គេស្រាប់តែមានកម្លាំងពីណាមកទេក៏ស្ទុះក្រោក។ ទោះបីពន្លឺពេលនេះមើលឃើញគ្រប់យ៉ាងមិនច្បាស់ តែនាងឃើញរាងកាយធំខ្ពស់របស់នាយ និងក្លិនទឹកអប់ដ៏ទាក់ទាញស្រាលស្ទើកអណ្តែតអណ្តូងចិត្ត។ បុរសនេះតាមពិតជាប្រុសស្អាតម្នាក់ក្នុងបេះដូងលោតភ្លឹករបស់នាង។

គេមិនរវល់នឹងកែវភ្នែកម៉ក់ៗនៃស្រីតូចដែលភាន់ភាំងនិងសម្រស់ខ្លួនឡើយ។ ប្រុសស្អាតចាកចេញចោលនាងទាំងមិននិយាយស្វាគមន៍សូម្បីតែមួយម៉ាត់ តែគេដើរបានប៉ុន្មានជំហានប៉ុណ្ណោះក៏ដួលរេលទៅវិញដូចដើម។

នៅពេលដែលម្ចាស់ផ្ទះអនាគត កំពុងចំហមាត់ធ្លុង នាងបានសម្គាល់ឃើញថាបុរសនេះ ហាក់ត្រូវរបួសប្រឡាក់អាវខាងស្តាំ ជោគខ្មៅ មិនដឹងជាញើស ឬឈាមឱ្យប្រាកដ ជាមួយនោះ ដៃគេដែលបាត់ដៃអាវម្ខាងហាក់បីដូចជាកម្រើកមិនសូវបានល្អ។

គេដេកស្ងៀម ដង្ហើមដង្ហក់ នៅតែប្រឹងស្រវាក្រោកគ្រាន់តែក្រោកមិនរួចត្រឹមត្រូវ។

សេចក្តីមេត្តាករុណាដែលកប់ជ្រៅ ក្នុងសន្តានចិត្តនារីតូចក៏បានបញ្ចេញឥទ្ធិពលបាំងបាត់ភាពឆ្ងឿងឆ្ងល់របស់នាង។ ទោះគេមើលទៅសោះកក្រោះមិនសូម្បីសម្លឹងមុខនាងដែលមានបំណងល្អ តែនារីនេះនៅតែចង់ជួយគេ។

«បងឯងកម្រើកធ្វើអី? ចាំខ្ញុំជួយ»

គេនៅធ្មឹងពេលនាងអោនមកកៀកនឹងកែវភ្នែក។ នារីនេះមានសម្រស់ធម្មជាតិ ដ៏អាចកំបាំងភ្ជាប់ជាមួយសំឡេងស្រទន់ពីរោះបង្ហាញនូវ ចរិតដ៏ត្រង់ទៅត្រង់មករបស់នាង។

«អ្នកណាធ្វើបាបបងឯង?»

សម្ដីនាងធ្វើឱ្យគេនឹកឃើញឡើងវិញដល់គ្រោះថ្នាក់ដែលទើបប្រទះជាដំបូងក្នុងជីវិត។ រហូតដល់ពេលនេះ អ្នកណាម្នាក់នៅពីក្រោយការទិញជីវិតរបស់ខ្លួន គេក៏មិនដឹងផង ចុះទម្រាំបើខ្លួនឈឺស្ពឹកក្រោកមិនបាន?

«ខ្លួនឯងជាអ្នកណា?»

គេសួរនាងវិញតិចៗទាំងជ្រួញចិញ្ចើមឈឺចាប់ពេលដែល កម្រើកមាត់និយាយ។

«បំពង់កបងឯងហូរឈាម?»

នាងនិយាយដោយផ្លាស់ទឹកមុខទៅជារន្ធត់សោកសៅ។ នរៈស្រវាយកម្រាមប៉ះទីដែលឈឺពើត។ វាជារបួសសើស្បែកតែវាក៏មិនមែនស្រាលៗដែរ។

នាងអោនមកគ្រាហ៍នាយឡើង។

«យកខ្ញុំទៅណា?»

គេសួរតិចៗទាំងអស់សង្ឃឹម។

ស្ថានភាពនេះ បើឱ្យពួកមនុស្សអាក្រក់រកឃើញ តើមានមធ្យោបាយអីនឹងតស៊ូទៀត?

ស្នូរសត្វបក្សាបក្សីរិលរកទ្រនំយំរំពងធ្វើឱ្យបរិយាកាសរឹតតែស្រងេះស្រងោច។ ក្នុងកែវភ្នែកស្រីតូចលេចចេញនូវដំណក់ទឹកថ្លា រលីងរលោង៖

«ខ្ញុំជួយបងឯងហ្នឹងណ៎ា!»

រស្មីព្រិចៗនៃទឹកនេត្រាស្រីស្អាតចាំងផ្លេកៗ ជ្រែកភាពងងឹត ធ្វើឱ្យបេះដូងតារាធ្លាក់ចាកមេឃទៅជាទន់ច្របល់។ គេសួរទាំងក្បាលកើយលើរង្វង់ដៃនាងបីត្រកង៖

«យើងមិនដែលស្គាល់គ្នា យំធ្វើអី?»

នាងដកដង្ហើមលាន់ស្នូរសម្លេងរគ្រូក ហើយឆ្លើយ៖

«ខ្លួនជិតស្លាប់ហើយនៅមិនដឹងទៀត!»

Lorenzoចងចិញ្ចើមហួសចិត្ត៖

«អ្វះ? .....អូខេ ! មិនបាច់ជួយក៏បាន បើគង់តែដាក់បណ្ដាសាដដែល!»

នាងសម្រួលឥរិយាបថព្រោះជ្រុលនិយាយមិនបានគិត តែនាងពិតជាមានភាពអាណិតអាសូរនាយតាមកែវភ្នែកមិនដាច់ស្រេចសោះ។

«ខ្ញុំមានថ្នាំឃាត់ឈាមនៅផ្ទះ!»

ថាចប់ស្រីស្អាតប្រឹងត្រកងបុរសនេះក្រោកទាំងត្រដាបត្រដួស។

គេប្រឹងតស៊ូក្រោកជាមួយនាង រហូតដល់ឈរបានទាំងស្រែកថ្ងូរឈឺចាប់នឹងមុខរបួស។

«ត្រូវត្រង់ណាខ្លះ!»

នាងសួរទាំងទទួលអារម្មណ៍ហាក់ឈឺជំនួសនាយ ប៉ុន្តែបុរសនេះមិនឆ្លើយ បែរជាព្យាយាមឃាត់មិនឱ្យនាងដើរបន្តទៅមុខ។

គេសំកាំងមិនព្រមទៅហើយនិយាយខ្សឹបៗ៖

«សន្យាបានទេ?»

«ម៉េចស្គាល់ឈ្មោះខ្ញុំ?»

គេមិងមាំងព្រោះមិនដឹងឡើយថា នាងឈ្មោះ«សន្យា»។

«ខ្ញុំឱ្យខ្លួនឯងសន្យា!»

«ឱ្យអីខ្ញុំ?»

គេហាក់ធុញទ្រាន់ ណាឈឺរបួស ណានឿយចិត្តនិងនាងច្រមក់ ប៉ុន្តែភ្នែកនាងខ្មៅក្រឹបទំនងជាមនុស្សមានចិត្តថ្លើមស្មោះត្រង់ ទើបបណ្ដាលចិត្តគេឱ្យតស៊ូពន្យល់៖

«ខ្ញុំឱ្យខ្លួនឯងជួយ តែត្រូវព្រមសន្យាថាមិនប្រាប់អ្នកណាទាំងអស់!»

នារីនេះយល់ពីអ្វីដែលគេកំពុងតែចង់មានន័យហើយ។ នាងនៅស្ងៀមព្រោះមិនដែលមានមនុស្សឯណាបានគេជួយហើយដាក់លក្ខខណ្ឌទៀតនោះទេ។

នាងក្រញូវ មិនមាត់ បុរសនេះផ្ដួនបន្ថែមៈ

«អ្នកណាក៏ដោយ!»

គេបញ្ជាក់ធ្វើឱ្យនាងកាន់តែធុញទ្រាន់។ ទោះយ៉ាងណារាងកាយគេហាក់ដូចចង់ញាក់ទៅតាមកម្រិតអាកាសធាតុដែលប្រែប្រួលរហ័សនៃតំបន់ព្រៃភ្នំ ហើយគេចាប់ផ្ដើមឡើងកម្ដៅពីខាងក្នុង។ នាងប្រញាប់ប្រញាល់ដកអារម្មណ៍ចេញពីការអង្គាសចិត្តគ្នា ហើយកំណត់សុខុមាលភាពនាយជាអាទិភាពវិញ។

«តោះទៅ!»

នាងបណ្ដើរបុរសនេះទៅចំពេលដែលគេចាប់ផ្ដើមងងឹតមុខបន្តិចៗម្ដង។

នាងបម្រុងថា នាំគេទៅផ្ទះ ដឹងអីសម្ដីគេមុននេះហាក់រំលឹកនាងឱ្យគោរពពាក្យដែលគេស្នើសុំ។

«មនុស្សនេះឫកធំណាស់! មុនសន្លប់ឆ្លៀតបញ្ជាខ្ញុំបានទៀត!»

ប្រុសស្អាតលែងមាត់ក បណ្ដោយឱ្យនាងបណ្ដើររហូតដល់ខាងលើហើយខ្សឹបផ្ដាំ។

«នៅឱ្យស្ងៀម! បើមិនចង់ឱ្យអ្នកណាឃើញ ត្រូវទៅឆ្ងាយបន្តិច! ចាំហ្នឹងហើយខ្ញុំទៅយកម៉ូតូ!»

បុរសត្រូវបាននាងដាក់អង្គុយលើដង្គត់ឈើ ប្របមាត់ផ្លូវ ហើយមិនយូរប៉ុន្មាននាងវិលត្រឡប់មកវិញជាមួយម៉ូតូដែលធ្លាប់បញ្ជិះប្រធាននិស្សិតឈុនរាជ។

«តោងខ្ញុំឱ្យជាប់! ខំឡើងណា!»

ផ្ទះអនាគត នៅឆ្ងាយប្រមាណជាងមួយគីឡូពីភូមិនៃប៉ប្រះនឹងមាត់ព្រៃ។

«ម៉ូតូខ្ញុំមួយរយៈនេះដឹកអ្នកភ្នំពេញញឹកដល់ហើយ!»

គេបើកភ្នែកមកវិញភ្លាមទោះងងឹតមុខបែបណាក៏ដោយ។ សមាសភាពខ្លួនជារឿងដែលត្រូវពិបាកចិត្ត គេសួរខ្សោយៗៈ

«ម៉េចដឹងខ្ញុំអ្នកភ្នំពេញអ្ហះ?»

«ក្លិនទឹកអប់បងឯង សាច់ឈាមបងឯង!»

នាងឆ្លើយវិញធ្វើហី មិនរវល់និងការភ័យបារម្ភដែលកំពុងមានសន្ទុះកើនឡើងក្នុងចិត្តនាយអ្វីបន្តិចឡើយ។

នរៈរូបនេះកំពុងតស៊ូនិងការឡើងកម្តៅរាងកាយក្បាលឈឺស្ទើរបែកភ្នែកព្រិលស្រវាំងតែគេនៅខំប្រើដង្ហើមតិចតួចនេះ រិះរកមធ្យោបាយ។ ចុងក្រោយគេនៅតែគ្មានធ្វើអ្វីបានក្រៅពីនិយាយជាមួយនាងដាច់ៗដោយផ្តេកមុខលើស្មាស្រីតូច៖

«ខ្លួនឯងសន្យារួចហើយ ថាមិនប្រាប់អ្នកណាពីរឿងបង!»

នារីដៀងភ្នែកមកមើលគេ។ ចិត្តនាងរិះគិត តើបុរសនេះមកពីណា ត្រូវអ្នកណាតាមបានជាគេចចេសរឿងលាក់ការណ៍ម្ល៉េះសូម្បីតែ មុនពេលបិទភ្នែកស្លុងទៅ។

«បងឯងឈ្មោះអី?»

គ្មានចម្លើយ។

នាងក៏លែងសួរបន្ថែមល្បឿន តម្រង់សាលាព្រោះដឹងថាគេលែងស៊ូបានហើយ។

នៅក្នុងសាលាគ្មានអ្នកណានៅព្រោះពេលនេះយប់ហើយ ក្មេងៗ បែកក្រុមវិលទៅរកផ្ទះរាងខ្លួននៅបន្សល់តែក្តារខៀនធំដែលក្រវេមក្រវាមទៅដោយភាសាអង់គ្លេសថ្នាក់មត្តេយ្យ។

ភាគទី៣៨

វគ្គ ហោរា

ចិត្រាពាក់ឯកសណ្ឋានឈរមុខកញ្ចក់ ផ្ទៀងផ្ទងសម្លឹងសក្តិលើស្មារបស់ខ្លួនទាំងមុខទោមនស្ស។ បញ្ហាជាច្រើនកំពុងជាចំណោទមិនចេះចប់កើតមានក្នុងចិត្តនាយ ហើយដែលធំជាងគេក្នុងពេលនេះគឺសុវត្ថិភាពឯកមាននិងផានូ។ គេធ្វើដំណើរមកផ្ទះឧត្តមសេនីយ៍ដើម្បីបំពេញការងារ តែមិនទាន់បានចុះពីម៉ូតូស្រួលបួលផង គេឃើញ អមរាដាបង្ហាញខ្លួនពីចម្ងាយ។

«បងឈុនរាជចាំនៅខាងក្នុង!»

នាងនិយាយទាំងទឹកមុខស្រពោនធ្វើឱ្យនរៈនឹកខ្លោចចិត្តអាណិតធីតាអភិជនដែលត្រូវព្រាត់និរាសមិត្តទាំងគ្មានហេតុផល។

បុរសនេះមិនមាត់មិនករតែគេអោនគោរពស្រីស្អាតមុនពេលឈានចូលទៅកាន់បន្ទប់ទទួលភ្ញៀវ។

«ឮថាពូសាម៉ុនឱ្យឯងនាំប៉ូលិសទៅរកឯកមាន បងឈុនរាជសុំនាំផ្លូវទៅ!»

នាយឈុនរាជហៅខ្លួនឯង«បងៗ»មិនមានក្រែងរអែងអ្នកណាធ្វើឱ្យនាយសក្តិប្អូនដែលកំពុងកើតទុក្ខសឹងថា អស់សំណើចម្តងៗបាន។

«ល្អហើយបានកម្លាំងច្រើន!»

គេឆ្លើយខ្លីៗទាំងដៃលើទូរសព្ទមកពិនិត្យព្រោះឮសំឡេងSMS។ មិនទាន់បានពិនិត្យផងស្រីស្អាតអមរាដាឈានមកក្បែរធ្វើឱ្យអង្គរក្សងើបមុខសម្លឹងនាង។

ស្រីស្អាតនិយាយមួយៗទាំងស្រពាប់ស្រពោន៖

«ជាក់ស្តែងខ្ញុំអ្នកខុស!»

បុរសនេះជ្រួញចិញ្ចើម។ ឫកពាគេមានភាពស្មុគស្មាញច្រើនជាងកាលពីមុនពេលជួបនាងម្តងៗ ដូច្នេះហើយអមរាដាដែលបានកើតទុក្ខខ្វល់ខ្វាយរឿងផានូប៉ុន្មានថ្ងៃមកនេះ កាន់តែទទួលអារម្មណ៍ថាខ្លួនឯងមានកំហុស ក្នុងការជំរុញឱ្យមិត្តភក្តិទៅចូលរួមសមោសរ ព្រោះសំអាងថាពឹងលើបងឈុនរាជ។

ហាក់មានខ្លួន ឈុនរាជធ្វើជាក្រោកចេញហើយងាកផ្តាំ៖

«បងទៅរៀបចំហើយ! ចេញទៅពេលណាហៅបង បងនៅក្រៅកន្លែងពូហឿន!»

«ទុកឱ្យខាងប៉ូលិសគេធ្វើ! បងឯងទើបនឹងរួចមក គួរសម្រាកខ្លះទៅ មានរឿងអីចាំខ្ញុំផ្តល់ដំណឹងទៅ!ខាងខ្ញុំមិនបាច់ភ័យទេ ខ្ញុំមានកម្លាំងខ្លះទៅតាមហើយ »

គេដឹងថា ចិត្រាមិនព្រមឱ្យខ្លួនចូលរួម ដូច្នេះមុននឹងចេញគេងាកមកវិញ ជាមួយទឹកមុខស្រពោន ហើយវាចា៖

«នៅក្នុងឡានមុនពេលបែកគ្នា ឯកមានធ្លាប់និយាយថា ពួកអ្នកចាប់ស្រីៗជាប៉ូលិស! ឯងកុំស្ងួវទុកចិត្តពួកហ្នឹងពេក»

ចិត្រាជ្រួញចិញ្ចើមគិត ឃើញដូច្នោះឈុនរាជឈោ្វកមុខនិយាយបន្ថែម៖

«របាយការណ៍ពិស្តារខ្ញុំបាននិយាយនឹងប៉ូលិសអស់ហើយ អ្វីដែលខ្ញុំបានឃើញ! ឯងកុំភ្លេចអានផងក្រែងមានពន្លឺរកមិត្តឯងឃើញ!»

មនុស្សទាបកន្ទៀហាក់មានវិប្បដិសារីជាខ្លាំងក្នុងការបាត់បង់ឯកមាន និងផានូ។ គេបាត់បង់ឫកពាក្រអឺតក្រទមនិងចរិតឡូយឆាយហើយដើរមួយៗ ចាកចេញស្ងួយៗទៅក្រៅផ្ទះ។

ចិត្រាពិតជាចង់ដឹងណាស់ថាគេទាំងបីបានឆ្លងកាត់ឧបសគ្គអ្វីខ្លះមុនពេលបែកគ្នារហូតពេលនេះបានជាបងធំកាងសាលាដូរឥរិយាបថមកជាមនុស្សគួរឱ្យអាណិតបាន?

ឥឡូវនេះនៅសល់តែកំលោះ និងក្រមុំទាំងទ្វេក្នុងបរិវេណគេហដ្ឋាននេះ។

គេកំពុងពិបាកចិត្តស្រាប់អ៊ីចឹងហើយនាយអាចយល់ដល់ពីទំហំទុក្ខខ្វល់ខ្វាយរបស់នាង។

«អ្នកនាងខុសរឿងអីទៅ»

«ខ្ញុំមិនព្រមស្តាប់បងឯងតាំងពីដំបូង!»

នាយសក្តិប្ដូនរំភើបចិត្តដែលត្រូវបានស្រីស្អាតមកសារភាពទទួលស្គាល់កំហុសភ្លាមៗហើយនាងមើលទៅហាក់បីដូចជាមានទំនុកចិត្តលើនាយជាងពេលមុនៗ។

«ពួកនោះមានឧបាយកលខ្ពស់! មិនមែនជាកំហុសអ្នកណាទេ ឈប់បន្ទោសខ្លួនឯងទៅ!»

នាងនៅប្រិចភ្នែកចុះឡើងហាក់ពេញដោយវិប្បដិសារី ធ្វើឱ្យចិត្តអង្គរក្សចង់តែលូកទៅចាប់កាន់ដៃនារីនេះថ្នមៗបង្កើនភាពកក់ក្ដៅឱ្យនាងគ្រាន់តែគេមិនហ៊ាន។

បុរសព្យាយាមទម្លាក់ចោល ភាពខ្វល់ខ្វាយហើយនិយាយមួយៗ៖

«ពីរនាក់គេមិនអីទេ! ហើយខ្ញុំច្បាស់ជាធ្វើអីមិនកើតឡើយ បើអ្នកដែលបាត់ខ្លួនទៅនោះប្ដូរមកជាអ្នកនាងអមរាដា!»

ស្រីស្អាតងាកមកភ្លាម ព្រោះមិននឹកស្មានថាបុរសនេះនឹងហ៊ាននិយាយពាក្យដូច្នេះចេញមកបាន។ជាការពិតណាស់ គេក៏មិនដឹងខ្លួនដែរថាអាថ៌កំបាំងនៃមនោសញ្ចេតនាដែលលាក់ទុកក្នុងបេះដូងរមែងអាចបែកធ្លាយចេញក្នុងគ្រាណាមួយដែលខ្លួនកំពុងស្ថិតក្នុងស្ថានភាពស្មុគស្មាញខ្លាំង។

បានជាជ្រុលនិយាយទៅហើយគេថែមទាំងមានអារម្មណ៍ថាមានកំហុស ប៉ុន្តែជាកំហុសដែលធ្វើឱ្យសប្បាយចិត្តហើយមិនចង់ថយក្រោយវិញឡើយ៖

«អ្នកនាងត្រូវនៅក្នុងផ្ទះកុំចេញទៅណា ប្រសិនពិតជាយល់ចិត្តខ្ញុំ! ខ្ញុំទុកសុវត្ថិភាពអ្នកនាងដូចជាជីវិតខ្លួនឯង!»

ស្រីស្អាតនៅនឹងថ្កល់ប្រទាក់ភ្នែកនឹងនាយ។ តាមថាបុរសនេះរងសម្ពាធណាស់ពេលដែលមកលង់ស្នេហ៍ព្រះនាងឋានព្រះចន្ទ ប៉ុន្តែសេចក្តីស្នេហាវារមែងថាអាចទម្លុះបានរនាំងគ្រប់យ៉ាង ពេលនេះទៀតសោត ទាំងសងខាងកំពុងស្ថិតក្នុងទុក្ខសោក គេមិនចង់ងាកភ្នែកចេញទៅណាពីនាងឡើយគឺចង់នៅរង់ចាំរហូតដល់ តែឃើញប្រាកដថានាងបានធូរស្រាលចិត្តឡើងវិញទើបគេអាចធូរខ្លួនឯង។

«ទាល់តែបងឯងឆាប់មកវិញ! មិនអ៊ីចឹងខ្ញុំមិនគេងទេ!»

បេះដូងនាយស្រយុតស្រយង់។ នារីនេះក្មេងសេចក្តីតែអ្វីដែល នាងនិយាយគឺស្មោះត្រង់ហើយចេញពីជម្រៅបេះដូង។

ពេលនេះទូរសព្ទមិនត្រឹមតែSMSទេ ប៉ុន្តែរោទ៍តែម្តង។

គេដកកែវភ្នែកចេញពីនាងយឺតៗហើយឈ្ងោកមកសម្លឹង។ ចិញ្ចើមគេជ្រួញចូលគ្នាព្រោះ ពូគេមិនដែលទាក់ទងមកងាយៗទេ ពេលនេះគាត់មិនត្រឹមSMSហើយនាយមិនបានអាន ក៏ទូរសព្ទមកតែម្តង។

ទើបនឹងចុចទទួលមិនទាន់បានហាសូម្បីតែមួយម៉ាត់ណា សំឡេងពូគេលាន់មកមុនទៅហើយ៖

«ពូចង់ជួបឯងចិត្រា!»

«បាទ?»

គេឆ្លើយទាក់ទើរព្រោះមិនយល់ការណ៍។ ឧត្តមសេនីយ៍ចូលនិវត្តន៍មិនដែលខលមកសោះ ស្រាប់តែពេលនេះ ប្រាប់ថា «ចង់ជួប» ខ្លីកំបុតក្នុងកាលៈទេសៈដែលនាយត្រូវរ៉ាប់រងរឿងជាច្រើន មិនឱ្យកូនប៉ូលិសភាន់ភាំង?

យល់ពីកាលៈទេសៈ សេតវិទូនិយាយមកទៀត៖

«កូនធម៌របស់មិត្តពូនៅអាមេរិកគេមានគ្រោះភ័យហើយ! ជំនួយការគេទើបនឹងខលមក!»

អារម្មណ៍មួយប្រាវរបស់ វិទូនឹកភ្នកឃើញភ្លាមទៅដល់Lorenzo។ ជំនួយការវឌ្ឍនៈកំពុងក្នុងដៃប៉ូលិស គេម៉េចក៏ផ្ដល់ដំណឹងទៅពូខ្លួនលឿនម្ល៉េះ មានតែគេដឹងថាចៅហ្វាយគេកំពុងត្រូវអ្នកណាធ្វើបាប?

អមរាដាឃើញនាយស្ថិតក្នុងសភាពស្មុគស្មាញ នាងធ្វើដៃស៊ីញ៉ូថានិយាយទូរសព្ទសិនចុះនាងដកថយសិនក៏បាន។

នាងមិនទាន់បានឈានចេញទៅផង សំឡេងលោកឌិត សាម៉ុនលាន់ឮៗមកពីមាត់ទ្វារ៖

«ចិត្រា! ខ្ញុំមានតម្រុយថ្មីត្រូវការឱ្យលោកទៅជាមួយ! រឿងពីក្រោយគម្រោងការអាថ៌កំបាំងរបស់lorenzo!»

ឌិត សាម៉ុន និងRoy បង្ហាញខ្លួននៅមាត់ទ្វារ ធ្វើឱ្យ វិទូកាន់តែវិលវល់។

ពីដំបូងបុរសនេះឱ្យខ្លួនថយចេញពីករណីរបស់Lorenzoហើយទទួលភារកិច្ចស្វែងរកដំណឹងឯកមាន ពេលនេះគាត់បង្ហាញខ្លួនមកវិញដូចអំពិលអំពែក ហើយឱ្យខ្លួនរួមដំណើរក្នុងពេលដែលឪពុកមាកំពុងត្រូវការ?

«ខ្ញុំមានការបន្ទាន់ផ្សេងទាន!»

គេឆ្លើយជាមួយឌិត សាម៉ុន ។

ឧត្តមសេនីយ៍ដែលទើបនឹងចូលមកដល់ហើយរលះរលាំងទៅប្ដូរអាវស៊ីវិលនោះ ស្រាប់តែទច់ង៉ក់ភ្លាមពេលឮពាក្យចិត្រាបដិសេធ។

ភ្នែកគាត់ ដៀងមករកទូរសព្ទដៃដែលនៅក្បែរត្រចៀកនាយសក្តិបួនទំនងជាគាត់កំពុងប្តូរមកចាប់អារម្មណ៍ថាអ្នកណាទៅដែលខលមកក្នុងពេលនេះ?

រិទ្ធដែលសំងំបានបន្តិចហើយនេះខ្សឹបដាក់ក្អួយ៖

«អត់អីទេ! ទៅជាមួយគេសិនទៅ ! ហើយរឿងដែលពូខលទៅនេះ កុំប្រាប់គេឱ្យសោះ! ចាំសម្តីពូ!»

នៅខាងស្តាំដៃRoyញញឹមគួរសមដាក់គូដណ្តឹងតែគេមិនបាននិយាយអ្វីជាមួយនាងដូចមុនឡើយ។ស្នងការថយទៅអង្គុយលើសាឡុងរង់ចាំលោកឱត សាម៉ុន ចំណែកអមរាដាសួរនាំ៖

«បងRoyពិសាកាហ្វេ ឬតែ?»

ពេលនេះស្នងការចេះពិបាកចិត្ត គឺនៅពេលដែលគេចេះមានស្នេហាជាមួយនារីសិចស៊ីម្នាក់នោះ  គំនិតគេលែងមានជាមួយចំណងអាពាហ៍ពិពាហ៍ដែលហៀបនឹងចាប់ផ្តើមឡើងនេះ។ជំហានដំបូងរបស់គេគឺរកគ្រប់វិធីឱ្យខ្លួនអាចផ្តាច់ពាក្យយកសេរីភាពមកវិញ ហើយមិនខូចខាតដល់ទំនាក់ទំនងសងខាង ចំណែកការដែលថយឆ្ងាយៗ ពីអមរាដាជាអ្វីដែលត្រូវធ្វើក្នុងពេលនេះ។

«អរគុណណាស់! តែខ្ញុំប្រញាប់ចេញប្រតិបត្តិការ!»

Royឆ្លើយតបសុភាពរាបសារ ហាក់មិនបានព្យាយាមមកក្បែរៗនាងដូចពីពេលមុន ធ្វើឱ្យអមរាដាហាក់ធូរចិត្តដោយមិនចាំបាច់រត់គេចចេញ។

នាងនៅទីនេះពិនិត្យអ្វីៗដែលកំពុងកើតឡើងចំពោះចិត្រា។ អមរាដាសម្លឹងខោអាវស៊ីវិលលើខ្លួនគូដណ្តឹងដែលខ្លួនមិនពេញចិត្ត ចំណែកជាតិចិត្រាដែលនាងពេញចិត្តគេនៅក្នុងឯកសណ្ឋាន ប៉ូលិសនៅឡើយ ហើយឪពុកនាងមកហៅគេភ្លាម ឱ្យទៅជាមួយ បង្ហាញថាបុរសដែលនាងកំពុងមានចិត្តថ្លើមឱ្យម្នាក់នោះ មានសមត្ថភាពសំខាន់ណាស់ រហូតដល់ស្នងការមិនអាចជំនួសបាន។

ចិត្រាបិទទូរសព្ទស្របពេលលោកឱត សាម៉ុនបោះបង់ចោលការសម្លឹងនាយហើយរត់ឡើងទៅលើ។

សំឡេងគាត់បញ្ជាមកពីខាងលើ៖

«ស្លៀកពាក់ស៊ីវិលវិញទៅ!»

គេធ្វើតាមបញ្ជាទាំងទ្រូងធ្ងន់កណ្ដុកជាមួយនិងចម្ងល់ជាច្រើនប្រការ។

ឥឡូវនេះគាត់នាំនាយឡើងឡានហើយរួមទាំងស្នងការRoy ផងដែរ ឯខ្លួនគាត់ជាអ្នកបើកបរផ្ទាល់ផង ដូច្នេះករណីឯកមាន តើគិតយ៉ាងណា?

«មិញអ្នកណាខលមក?»

សំឡេងដ៏មានអំណាចរបស់បុរសនេះ ធ្វើឱ្យនាយងាកមកវិញភ្លែតហើយបម្រុងឆ្លើយតាមទម្លាប់ ដ៏ស្មោះត្រង់របស់ខ្លួន ប៉ុន្តែ រំពេចនោះគេនឹកភ្លាមដល់ពាក្យផ្ដាំខ្សឹបៗរបស់លោកមាជាទីគោរព របស់ខ្លួន «ហើយរឿងដែលពូខលទៅនេះ កុំប្រាប់គេឱ្យសោះ! ចាំសម្ដីពូ!»។

គេនៅទ្រឹង ក្នុងពេលដែលទទួលអារម្មណ៍ថា ពីរនាក់ទៀតអង្គុយក្នុងឡាននេះកំពុងរង់ចាំចម្លើយ។នាយសក្ដិបួនឆ្លើយភ្លាម៖

«មិត្តខ្ញុំម្នាក់! ខ្ញុំសួរនាំគេរឿងឯកមាន!»

«មិញលោកថាមានការបន្ទាន់ជាមួយគេនេះឬ?»

គាត់ហាក់យកចិត្តទុកដាក់ជាមួយរឿងដែលទើបនឹងកើតឡើង ហើយជជីកសួរ ប៉ុន្តែចិត្រាបង្វែងខ្លួនឯងថា នេះជាភាពវាងវៃ ម៉ត់ចត់របស់ប៉ូលិសគ្រប់គ្នាប៉ុណ្ណោះ។

គេវាចាតប៖

«បាទ! ខ្ញុំចង់ទៅរកគេ ព្រោះគេជាអ្នកចេះជំនាញដូចអាមាន!»

«គេឈ្មោះអី នៅនាយកដ្ឋានណា?»

ដល់ពេលដែលកុហកចង់ជាន់ដានខ្លួនឯងរកពាក្យនឹងតបមិនចង់បាន តែបំណាច់កុហកត្រូវកុហកឱ្យចប់ចុងចប់ដើម។ ចិត្រាតបវិញបន្ថែម៖

«វាមិនមែនប៉ូលិសទេទាន!»

ឱត សាម៉ុនងក់ក្បាលផ្ងក់ៗលែងចេញស្ដី។

ចិត្រាងាកសម្លឹងដងផ្លូវដែលបុរសចំណាស់កំពុងបញ្ជាយានយន្តដោយដៃឯង ចំណែកស្នងការRoyនៅសម្លឹងទូរសព្ទមិនចេញស្តី។

ពេលគេក្រឡេកទៅមួយឆ្វាច សក្តិបួនយើង ក្រឡេកឃើញរូបស្រីស្អាតដែលខ្លួនឯងហាក់ធ្លាប់ស្គាល់ក្នុងScreen របស់ស្នងការដែលអង្គុយនៅបាំងពីមុខខ្លួន។

«ពិធីការរបស់មហាវីន Rose? ចេញប្រតិបត្តិការហើយ ប៉ុនេះនៅលបមើលProfileស្រីៗទៀត?»

ហាក់ដឹងខ្លួនមកវិញ Roy លបមើលមកចិត្រាតាមកញ្ចក់ខាងមុខ ហើយប្រញាប់បិទទូរសព្ទ។

ដល់វេនចិត្រាបើកទូរសព្ទមើលSMSម្តង។ គេនៅខាងក្រោយប្រាកដណាស់ថាគ្មានអ្នកណាអាចឃើញពីអ្វីដែលពូគេបានសរសេរមកទេ។

«ចិត្រា! កូនធម៌របស់ជំនិតកំពុងមានរឿងធំ! ជំនួយការគេព្រឹកមិញត្រូវប៉ូលិសហៅសួរ! អាឡូវគេចេញមកក្រៅបានហើយ តែគេរកវីរៈមិនឃើញទេ! គេថា ឡានដែលឱ្យមកទទួលជំនិតវីរៈមិនបានធ្វើតាមការគ្រោងទុក ព្រោះអ្នកប្រុសគេបាត់ទៅមុនពេលឡានមកដល់ ពូត្រូវតែដោះស្រាយរឿងនេះ! ហើយនៅស្នងការប៉ូលិសមានរបាយការណ៍ច្រើនអាចចោទប្រកាន់គេបាន! ក្មេងនោះជាន់ដានចាស់ប៉ាគេហើយ! អ្នកណាម្នាក់កំពុងធ្វើបាបគេហើយ ពូគិតថា អាចក្នុងចំណោមពួកប៉ូលិស!»

កែវភ្នែកឱត សាម៉ុនបង្ហាញមកពីក្នុងកញ្ចក់ខាងមុខធ្វើឱ្យដៃនាយរហ័សដូចផ្លេកបន្ទោរចុចទូរសព្ទបិទបំបាត់ដាន។

មិនដឹងជាយ៉ាងណា អ្វីម្យ៉ាងបានបណ្តាលឱ្យចិត្រាជឿថាលោកមាខ្លួនមុខតែមានហេតុផលសំខាន់ណាមួយ មិនខានក្នុងការដែលគាត់ហាមាត់ហាម មិនព្រមបណ្តោយឱ្យខ្លួននិយាយរឿងអស់នេះប្រាប់អ្នកណា ហើយ១០០ភាគរយ ខ្លួនជឿលោកមាជាងអ្នកណាទាំងអស់ក្នុងលោកនេះក្នុងដំណើរការរឿងក្តី។

គេលើកក្រចកដៃមកខាំបន្លំទឹកមុខដែលកំពុងលាក់កំបាំងការគិតជាច្រើនជំពូក។

សម្តីឈុនរាជដែលទើបនឹងផ្តាំកាលពីនៅខាងក្នុងផ្ទះ លាន់ត្រឡប់មកវិញ«នៅក្នុងឡានមុនពេលបែកគ្នា ឯកមានធ្លាប់និយាយថា ពួកអ្នកចាប់ស្រីៗជាប៉ូលិស! ឯងកុំសូវទុកចិត្តពួកហ្នឹងពេក »

ហេតុអ្វីសម្តីលោកមា និងឈុនរាជមានចំណុចស្របគ្នា?

តើលោកឱត សាម៉ុនដឹងរឿងនេះដែរទេ? គាត់ដឹងរឿងដែលថាឯកមាន មុនបាត់ខ្លួនទៅបានសង្ស័យ លើពួកប៉ូលិសថានៅពីក្រោយការចាប់ស្រី?

«លោកនាយបានទទួលរបាយការណ៍របស់ឈុនរាជ?»

គេសួរតិចៗធ្វើឱ្យRoy និងលោក ឱតសាម៉ុនងើបមុខមកមើលតាមកញ្ចក់ព្រមគ្នា។

ឧត្តមសេនីយ៍ឆ្លើយមុន៖

«ឈុនរាជ ត្រូវគេវាយសន្លប់ហើយដឹងខ្លួនឡើងនៅក្នុងល្អាងនោះបាត់ទៅហើយ!»

«គេមានចេតនាឱ្យឈុនរាជដោះលែងចំណាប់ខ្មាំង!»

ចិត្រាភ្លាត់មាត់ហើយរវេីកគិតចុះឡើង ត្រចៀកគេនៅរង់ចាំស្តាប់បន្ត ហើយជាមួយនឹងការតាមដានប្រតិកម្មប៉ូលិសទាំងពីរមិនរំលងផងដែរ។

«មុនពេលឈុនរាជបែកពីឯកមាន ពួកគេធ្លាប់បានជួបប៉ូលិសដែលព្យាយាមដាក់វត្ថុអ្វីមួយទៅក្នុងឡានរបស់ពួកគេដើម្បីផ្តាច់ទំនាក់ទំនងមកក្រៅ! អ្នកទាំងនោះប្រើឯកសណ្ឋានប៉ូលិស!»

រង់ចាំឱត សាម៉ុននិយាយចប់សឹងមិនទាន់ ចិត្រាវាចាបន្ថែម៖

«មុនចេញមក គេមករកខ្ញុំដែរ! ប្រធាននិស្សិតម្នាក់នោះ! គេអះអាងថាមុនបែកគ្នា អាមានវាយតម្លៃថាពួកអ្នកតាមធ្វើបាបគេជាប៉ូលិស! »

ស្នងការRoyនៅតែមិននិយាយអ្វីសូម្បីតែមួយម៉ាត់ណា។

តែលោកឱត សាម៉ុនទាក់ទងមកចិត្រាតាមផ្ទាំងកញ្ចក់រហូត។ គាត់សម្លឹងគេមុតមុនពេលងក់ក្បាលទទួលស្គាល់ហើយនិយាយ៖

«អ្នកមកចាប់កូនខ្ញុំ ប្រើឯកសណ្ឋានប៉ូលិស Hackប្រើលេខរបស់ប៉ូលិសដែលកូនខ្ញុំទុកចិត្ត ! ហើយអ្នកទៅស្នាក់ឯកមានក៏ជាប៉ូលិស ថ្លើមវាមិនតូចទេ! តែខ្ញុំនៅមិនទាន់មានចំណុចលំអិតណាមួយអាចយល់ព្រមជាមួយឯកមាន និងលោកដែលថាអ្នកនៅពីក្រោយរឿងអស់នេះជាប៉ូលិស!»

សាជាថ្មី គេនឹកដល់លោកមា។ «លោកមា» ពិតណាស់ គាត់ប្រាកដជាមានការបញ្ជាក់គ្រប់គ្រាន់មុនពេលហ៊ានសន្និដ្ឋានថា មេខ្លោងធំ អាចក្នុងចំណោមពួកប៉ូលិស។

គេចង់ជួបសេតវិទូក្នុងពេលនេះទាន់ចិត្តប្រាស់ប្រាល់ តែរថយន្តរបស់ឧត្តមសេនីយ៍អែបឈប់.....ចិត្រាសម្លឹង ទិដ្ឋភាពសងខាងផ្លូវគេទទួលអារម្មណ៍ថាទីនេះធ្លាប់មកហើយចុងក្រោយគេនឹកឃើញ។

«យើងមិនមែនមករកតាហោរម្នាក់នោះទៀតទេដឹង?»

គេសួរទាំងចិត្តប្រឫក ធ្វើឱ្យRoyងាកមកខ្ញាច់ហើយ សង្ហើញ ៖

«ឯងធ្លាប់ជួបគាត់?»

ចិត្រាមិនឆ្លើយ គេងើបមុខសម្លឹងឧត្តមសេនីយ៍។លោកឱត សាម៉ុន អោនរៀបចំឡានផងនិយាយមួយៗប្រាប់មកចិត្រា៖

«យើងបានសួរចម្លើយ ជំនួយការរបស់Lorenzo! គេសារភាពថាចៅហ្វាយកំលោះគេនោះព្រមមកភ្នំពេញព្រោះតែមានជំនឿងប់ងុលលើការស្វែងរកគូសង្សារ២៥នាក់ ម្នាក់ៗកើតឆ្នាំ២០០០!»

អស្ចារ្យណាស់ហើយ! គេស្ទាត់មាត់ដូចត្រូវចុក។ មនុស្សនៅដល់អាមេរិកមានលុយវាល់លានចេះបណ្ដាញស្ទាត់មកជឿរឿងចោលម្សៀតអស់ទាំងនេះមិនឱ្យចិត្រាត្រូវគាំងយោបល់?

ភាគទី៣៩

សម្ដីតាហោរដែលមានចរិតទ្រគោះ  បានលាន់មកវិញក្នុងការចងចាំរបស់នាយសក្ដិប្អូន៖

«នៅរាល់២០០០ឆ្នាំម្ដង មនុស្សស្រីពេញវ័យកើតឆ្នាំនេះ ជាមនុស្សដែលពួកអ្នករៀនវិជ្ជាអាគម ជឿថាពួកគេអាចរួមគ្នាកែប្រែវាសនាអ្នកណាម្នាក់ឲ្យក្លាយទៅជាអ្នកមានអំណាចផុត

កាលបាន! ចំនួន៣៥គឺជាការគុណ៧ដងនៅជ្រុងតូចៗរបស់ពួកផ្កាយ ពួកភូគព្ភសាស្ត្រជឿថា នេះគឺជាចំនួនខ្ពស់បង្អស់នៃក្បួនកែប្រែថាមពលរបស់ភពផែនដី! ចង់ដឹងវានោះនៅឯណា ជាអ្នកណា គួរចាប់យកមុំសំខាន់បី! មួយវាមានលុយមានអំណាច មានអ្នកចេះដឹងនៅក្បែរ ដែលអាចរៀបក្បួនបុរាណដឹងថាថាមពលមេឃដី ដឹងច្បាស់ក្បួនភូគព្ភហើយអាចមានសមត្ថភាពរៀបគម្រោង ចាប់ខ្លួនស្រីបួននាក់ស្អាតដូចញ្ញេចស្រមោច!»

ចិត្រានៅគាំងម្រាមដៃលើគែមទ្វារហើយគេនិយាយបដិសេធ៖

«មិនមែនLorenzoទេ!»

គេបដិសេធនេះពុំមែនមកពីលំអៀងចិត្តរឿងអាណិកជននោះជាញាតិដែលពូខ្លួនកំពុងរកមធ្យោបាយជួយនោះឡើយ តែខ្សែរឿងដែលប្រឌិតមកគឺមិនសមទំនងពិតមែន។

គេនិយាយបន្ថែម ព្រោះឃើញប៉ូលិសសក្តិធ្ងន់ទាំងទ្វេនៅទ្រឹងស្តាប់ខ្លួន៖

«Lorenzoអាចថាមានប្រាក់ក្រាលដើរ! គេណាត់ជួបស្រីៗ កុំថា៣៥នាក់ទោះ៥00នាក់ ទំនងជាអត់បញ្ហា ប៉ុន្តែ គេមានអំណាចអីចាប់បាត់ទាំងមនុស្ស ទាំងឡាន ទាំងកងការពារ! គេធ្វើបានប្រយោជន៍អី? ហើយបើគេខ្លាំងដល់ម្លឹង ពេលនេះទៀតសោត ហេតុអីគេចាំបាច់រត់ទុកជំនួយការឱ្យនៅជាប់ក្លេប៉ូលិស?»

Royសើចក្អាកក្អាយ ចំអកឱ្យការជជែកចុងក្រោយរបស់កូនប៉ូលិស។ ស្នងការម្នាក់នេះមានចរិតបែបនេះមកលើខ្លួនតាំងពីដើមរាងមក ហើយនាយតែងទុកមុខឱ្យគេជានិច្ច ព្រោះគោរពថានានុក្រម និងគោរពលោកឱតសាម៉ុន ជាអនាគតឪពុកក្មេកគេ ពេលនេះទៀតសោតចិត្តកំពុងតែបែងច្រើនរឿងគេចេះស្មុគ ហើយបែរជាលែងខ្វីខ្លាចគោរពអ្វីច្រើនទៀតដែរ។

នាយសក្តិបួននិយាយបន្ត៖

«លោកស្នងការអាចសើចចំអកឡកឡឺយខ្ញុំបានទាន តែខ្ញុំដឹងថាអ្នកណាម្នាក់ផ្សេងក៏កំពុងតែអោបដៃសើចចំអកឱ្យប៉ូលិសយើងដូចគ្នា!»

ឱត សាម៉ុនដឹងថា ចិត្រាយល់ពីល្បិចដែលបន្លាយខ្សែរញៀវញៀវរបស់ អ្នកដែលនៅពីក្រោយសេណារីយោនេះ ដូច្នេះទើបគេគិតថា កាលដែលនាំគ្នាចោលរឿងសំខាន់មកកន្លែងនេះទាំង

បីនាក់ ដូចជាកំពុងលេងសើច ខាតចោលពេលវេលាចូលក្នុងល្បិចរបស់ពួកអ្នកដែលកំពុងរៀបចំសាច់រឿងនៅទីងងឹតអ៊ីចឹងដែរ។

គាត់កាត់ផ្តាច់ទំនាស់យុវវ័យទាំងទ្វេដោយការពន្យល់វិញ៖

«ខ្ញុំដឹងថាវាកំពុងសើចយើងអ៊ីចឹងហើយខ្ញុំក៏ដរវាសើចលេងសិន!»

ចិត្រាចោលភ្នែកសម្លឹងស្នងការRoyដែលនៅតែសើចមិនឈប់ គេសង្កត់ចិត្តប្រាប់ខ្លួនឯងថាកុំឱ្យរវល់នឹងមនុស្សប្រភេទនេះ ដឹងអីស្នងការក្មេងនិយាយផ្ទួងមកកណ្តាលមុខនាយ៖

«ខ្ញុំថាឯងស្ទើរស្ទើរហើយ! គិតរាក់ៗ! គិតអីសើៗ! បើថាមិនចង់ទៅទេនៅចាំក្នុងឡានបាន!»

ចិត្រាដកភ្នែកចេញទាំងកំហឹងបញ្ចេញជាមួយស្នូរដង្ហើម។ គេរុញទ្វារចុះហើយអោនគោរពលោកឱតសាម៉ុន មុនពេលដើរទៅតាមគាត់ លែងខ្វីខ្វល់ពីអ្នកដែលចូលចិត្តជាន់កែងយកមុខ។

សាជាថ្មីពួកគេចូលមកដល់តំបន់ក្រីក្រជាមួយច្រកដ៏ចង្អៀតហើយជ្រៅសន្លឹម។ ពោរពេញក្រុមមនុស្សស្លេកស្លាំង ស្លៀកពាក់មិនសមរម្យ និងសំណង់រខេករខាកនៅរក្សាស្ថានភាពដដែលគ្រាន់តែបាត់ខ្ទមកំព្រូកលក់កាហ្វេនោះជំនួសមកវិញនូវការដ្ឋានសំណង់តូចមួយ។

លោកឧត្តមសេនីយ៍ បោយដៃហៅក្មេងជំទង់ម្នាក់ដែលកំពុងលើកស៊ីម៉ង់។ ចិត្រាដឹងថាគាត់សួររកតាហោសម្តីអាក្រក់ម្នាក់នោះ។

«នេះហើយផ្ទះអ៊ំពាង គាត់ទើបតែធ្វើ!»

សម្តីរបស់ក្មេងជំទង់ធ្វើឱ្យចិត្រានឹកឃើញដល់ឈ្មោះដើមគាត់ គាត់ឈ្មោះពាងពិតមែន។

«ប្រពន្ធគាត់ត្រូវឆ្នោត ហើយពេលនេះពួកគាត់ទៅលេងស្រុកថៃហើយ!»

បុរសទាំងបីមើលមុខគ្នាមុនពេលបណ្តើរគ្នាវិលត្រឡប់មករថយន្តវិញ។

ក្នុងគំនិតរបស់ចិត្រាអ្វីមួយមិនធម្មតា បានលេចចេញឡើងតាំងពីដំបូងពេលដែលលោកឱតសាម៉ុននិយាយថា ជំនួយការវឌ្ឍនៈសារភាពរឿង ទំនាក់ទំនងរវាងLorezoនិងតាហោ ប៉ុន្តែគាប់ជួនត្រូវRoyដៀមដាមបន្លប់ គេមិនបានវិភាគអ្វីច្រើនទេ។

ពេលនេះឈានមកដល់ក្នុងឡានហើយគេចាប់ផ្តើមនិយាយ៖

«អ្នកណាម្នាក់ បានបង្កើតគ្រូបោកប្រាស់នេះឡើងមក ហើយដៃម្ខាងមកប្រាប់ប៉ូលិសដៃម្ខាងបោកLorenzo!»

«លោកចង់សួរខ្ញុំថា ហេតុអ្វីខ្ញុំស្គាល់គ្រូពាង?»

ឱត សាម៉ុនសួរបកមកវិញ តែនាយសក្តិបួនក៏មិនបានបដិសេធ គេឆ្លើយតប៖

«បាទទាន! គេនោះគួរឱ្យសង្ស័យបំផុតថា ពាក់ព័ន្ធនឹងល្បែងបោកមួយនេះ ហើយត្រូវឆ្លងកាត់ការសួរចម្លើយ!»

«សោកស្តាយតានោះមករកខ្ញុំខ្លួនឯង!»

គាត់និយាយត្រឹមប៉ុណ្ណឹងក៏ល្មមឱ្យចិត្រាដឹងថាគាត់កំពុងសោកស្តាយដែលគិតយឺតៗ ហើយធ្លាក់ក្នុងល្បិចវិលវល់ជាមួយការរៀបចំដ៏ស្ទាត់នេះ។